## The Arc-C

**Association for Retarded Citizens-California**
**1228 - 8th Street, Suite 590**
**Sacramento CA 95814-2213**
**(916) 552-6619**

## PAI

**Protection & Advocacy, Inc.**
**100 Howe Avenue, Suite 185-N**
**Sacramento CA 95825**
**(916) 488-9950 ឬ**
**ទូរស័ពមិនអស់លុយ 1-800-776-5746**

Note: When this publication was originally published, we were known as Protection & Advocacy, Inc. (PAI). In October 2008, we changed our name from PAI to Disability Rights California.

5005.06
June 2001
Cambodian

# អភិរក្ស, ភារៈគ្រប់គ្រង ហើយនិងមត៌កសាសន៍សំរាប់ ឲ្យមនុស្សកើតមានភាពពិការ ឬភាពពិការផ្សេងៗទៀត - សៀវភៅណែនាំសំរាប់ក្រុមគ្រួសារ

**(Conservatorship, Trusts and Wills for People with Developmental or Other Disabilities — A Guide for Families)**

លោក Sterling L. Ross, Jr., អ្នកច្បាប់

ចាត់ចែងដោយ
សមាគមសំរាប់ប្រជាពលរដ្ឋពិការនៃរដ្ឋកាលីហ្វ័រនីញ៉ា (Association for Retarded Citizens-California)

បោះពុម្ពលើកទី 6
រៀបចំមួយផ្នែកឡើងវិញនិងបានបោះពុម្ពដោយ
**Protection & Advocacy, Inc.**



សមាគមសំរាប់ប្រជាពលរដ្ឋពិការនៃរដ្ឋកាលីហ្វ័រនីញ៉ា (Association for Retarded Citizens-California -ARC-C) ជាសមាគមមិនរកចំណេញ, រកផលប្រយោជន៍ឲ្យសាធារណៈដែលសហការថវិកាបង្កើតសមាគមនេះជាងសាមសិមឆ្នាំកន្លងមកដោយក្រុមមាតាបិតាដែលមានការព្រួយបារម្ភហើយនិងមិត្តភក្តិរបស់មនុស្សដែលមានវិកលចរិត។ សមាគម ARC-C ជាតំណាងឲ្យជាង 30,000 សមាជិកតាមក្រុមក្នុងតំបន់ដែលមានច្រើនជាង 65 កន្លែងនៅក្នុងរដ្ឋកាលីហ្វ័រនីញ៉ា។ បន្តរហូតមកគោលកម្លាំងរបស់សមាគម ARC-C គឺជាតំណាងឲ្យដំណើរការច្បាប់ទម្លាប់សាធារណៈដល់សមាជិករបស់ខ្លួន, តំណាងរាស្រ្ត, អ្នករដ្ឋការ ហើយនិងមន្ទីរ ព្យាបាលសុខភាពស្ម័គ្រចិត្ត ហើយនិងអង្គការផ្តល់កិច្ចបំរើដល់មនុស្សលោក។ បន្ថែមទៅលើការទាក់ទងច្បាប់, សមាគម ARC-C ផ្តល់ជំនួយខាងឯកទេស ហើយនិងកិច្ចបំរើដល់ក្រុមសមាជិកក្នុងតំបន់ជិតៗ ហើយតាំងខ្លួនជាផ្តល់ព័តមានផ្លាស់ប្តូរ តាមសន្និបាតតាមរយៈព្រឹត្តិប័ត្រ ជាច្រើនប្រភេទ, ការអប់រំដោយមានការពិភាក្សាគ្នា, ប្រជុំ, ការហ្វឹកហ្វឺន ហើយនិងសន្និបាតរដ្ឋប្រចាំឆ្នាំ។ ចង់បានព័តមានបន្ថែម សូមទាក់ទងមក :

**Association for Retarded Citizens-California (ARC-C)**
1228 - 8th Street, Suite 590
Sacramento, CA 95814
(916) 552-6619



**អ្នកជួលក្នុងលក្ខណៈទូទៅ។** ជាទំរង់ក្នុងការកាន់មុខងារដល់ទ្រព្យសម្បត្តិធំ ឬទ្រព្យសម្បត្តិផាល់ខ្លួន ដោយមនុស្សពីរនាក់ ឬច្រើនជាងនេះ។ ពីព្រោះតែមនុស្សដែលនៅរស់នោះគ្មានសិទ្ធិ, អ្នកមានទំនាក់ទំនងស្របច្បាប់, ហើយលិតផលបង្ហាញឡើងខុសប្លែកគ្នាពីអ្នកជួលរួមគ្នា។

**ម្ចាស់បណ្តាំ។** បុគ្គលដែលចុះហត្ថលេខាលើភារៈគ្រប់គ្រង ហើយចោលទ្រព្យសម្បត្តិរបស់ខ្លួន។ ពាក្យម្ចាស់ទ្រព្យគឺប្រើចំពោះអ្នកចុះហត្ថលេខាជាភេទស្រី ក៏ប៉ុន្តែ ដោយការងាយស្រួលប្រើពាក្យ អ្នកចុះហត្ថលេខានេះសំរាប់មនុស្សប្រុសនិងស្រីតែម្តង។

**ភារៈគ្រប់គ្រង។** មុខងារពេញច្បាប់ដែលបង្កើតឡើងការសរសេរសេចក្តីយល់ព្រមបានចុះហត្ថលេខា នៅពេលបុគ្គលនោះនៅរស់នៅឡើយ ឬដោយភារៈគ្រប់គ្រង។ ភារៈគ្រប់គ្រងគឺត្រួតពិនិត្យដោយលក្ខន្តិកនៅក្នុងឯកសារនោះ។

**អាណាត្តិព្យាបាលភាព។** បុគ្គលណាម្នាក់ ឬក្រុមហ៊ុនណាមួយដែលថែរក្សាមើលខុសត្រូវទ្រព្យសម្បត្តិក្នុងភារៈគ្រប់គ្រងនោះ។

**អ្នកគ្រប់គ្រង។ បុគ្គលដែលបង្កើតភារៈគ្រប់គ្រង។** អាចមានអ្នកគ្រប់គ្រងនេះច្រើនជាងម្នាក់។

**ភារៈគ្រប់គ្រងវត្ថុ។** ទ្រព្យសម្បត្តិដែលកាន់ក្នុងការគ្រប់គ្រង រួមទាំងគោលប្រាក់និងប្រាក់ចំណូល។

**មតិកសាសន៍។** ជាឯកសារដែលបុគ្គលម្នាក់ចុះហត្ថលេខាដើម្បីផ្តល់ឲ្យគេយកកេរ្តិ៍មតិកចោលក្រោយ ពីបានចែកឋានទៅ។

**បច្ឆាជន។** ជាទូទៅ កូនចៅតំណ; ប៉ុន្តែជាម្ចាស់បណ្តាំអាចក្នុងមត៌កសាសន៍ ចែងបច្ឆាជនរួមចូលទាំង កូនចិញ្ចឹមផង។

**ម្ចាស់ទ្រព្យរួមគ្នា។** ទំរង់ទ្រព្យសម្បត្តិដែលមានម្ចាស់ពីរឬច្រើននាក់ បានចាត់តាំងជា "ម្ចាស់នៃទ្រព្យរួមគ្នាមានសិទ្ធិទទួលផល"នៅពេលអ្នកមានទ្រព្យសម្បត្តិរួមគ្នានោះស្លាប់ ទ្រព្យសម្បត្តិរបស់គាត់ ត្រូវឲ្យទៅម្ចាស់ទ្រព្យរួមគ្នានៅរស់លើសហើយនិងហួសសិទ្ធិអំណាចនៃមត៌កសាសន៍ដែលម្ចាស់ ទ្រព្យសម្បត្តិរួមគ្នា, ទ្រព្យសម្បត្តិអាចប្រើប្រាសបានដោយគ្មានការជជែកព្យទុកឡើយ។

**សម្បត្តិរស់នៅ។** ចំណាង់ក្នុងទ្រព្យសម្ប័ត្តិរយៈពេលដែលគេថ្លឹងថ្លែងដោយរយៈជីវិតនៃមនុស្សដែល មានកេរ្តិ៍សម្បត្តិនៃជីវិត។

**មនុស្សនៅវ័យក្មេង។** នៅរដ្ឋកាលីហ្វ័រនីញ៉ា មនុស្សដែលមានអាយុក្រោម 18 ឆ្នាំ។

**ទ្រព្យសម្បត្តិផ្ទាល់ខ្លួន។** ទ្រព្យសម្បត្តិដែលផ្ទេរបាន ផ្ទុយទៅនិងទ្រព្យសម្បត្តិពិតប្រាកដ, ដែលជាក់ជាប់នៅមួយកន្លែង។ ទ្រព្យសម្បត្តិផ្ទាល់ខ្លួនរួមចូលសង្ហារឹម, គ្រឿងយន្ត ហើយនិងគ្រឿងសម្ភារៈផ្សេងៗ។

**សុពលកម្ម។** ពីធីតុលាការដែលតុលាការ????មានសិទ្ធត្រួតពិនិត្យមើលល្មើទ្រព្យសម្បត្តិដែលបានទុកពីអ្នកស្លាប់ ទៅអ្នកទទួលស្នងសម្បត្តិក្រោមមត៌កសាសន៍ ឬស្នងកេរ្តិ៍នៅពេលគ្មានមត៌កសាសន៍ទេនោះ។

**ទ្រព្យសម្បត្តិអចលន។** ការមានចិត្តលើដីធ្លី, ឬទ្រព្យសម្បត្តិដែលបានជាប់ទៅនិងដីធ្លី។

**ការប្រាក់នៅសល់។** ទ្រព្យសម្បត្តិដែលនៅសល់ក្នុងភារៈគ្រប់គ្រងក្រោយពីម្ចាស់មុន ឬអ្នកជួលរស់ នៅបានទទួលផលប្រយោជន៍ទ្រព្យសម្បត្តិដែលបុគ្គលនេះមានសិទ្ធទទួលនោះ។

**មនុស្សទទួលសម្បត្តិសេះសល់។** មនុស្សដែលមានសិទ្ធទទួលការប្រាក់នៅសេសសល់។

**ភារៈគ្រប់គ្រងអាចបដិសេធបាន។** ជាភារៈគ្រប់គ្រងដែលអាចផ្លាស់ប្តូរនៅលក្ខន្តិកៈ ហើយនិងច្បាប់ទម្លាប់។



ភ្នាក់ងារ Protection & Advocacy, Inc. (PAI) ជាភ្នាក់ងារឯកជន, ជាអង្គការមិនរក ចំណេញ ដែលការពារច្បាប់, ស៊ីវិល, ហើយបំរើសិទ្ធិដល់ប្រជាពលរដ្ឋពិការនៃរដ្ឋកាលីហ្វ័រនីញ៉ា។ ច្បាប់របស់រដ្ឋាភិបាលសហព័ន្ធបានតម្រូវឲ្យរដ្ឋនិមួយៗមានប្រព័ន្ធសំរាប់ការពារសិទ្ធិរបស់មនុស្សមានភាពពិការ។ ភ្នាក់ងារ PAI បានគេរើសយកធ្វើជាតំណាងក្នុងប្រព័ន្ធនេះក្នុងរដ្ឋកាលីហ្វ័រនីញ៉ា។ ភ្នាក់ងារ PAI ផ្តល់ឲ្យនូវកិច្ចបំរើការពារសិទ្ធច្រើនសន្ធានដល់មនុស្សមានភាពពិការ - រួមចូលការផ្តល់ព៌តមាននិងការបញ្ជូន, ជំនួយឯកទេស ហើយនិងធ្វើតំណាងឲ្យផ្ទាល់។ ចង់បានព៌តមានបន្ថែម ឬជំនួយ សូមទូរស័ព្ទមក :



**Protection & Advocacy, Inc. (PAI)**
**Toll Free (មិនអស់លុយ)**
**1-800-776-5746**
Central Office
100 Howe Avenue
Suite 185-N
Sacramento, CA 95825
(916) 488-9950

So. California Area Office
3580 Wilshire Blvd.
Suite 902
Los Angeles, CA 9001
(213) 427-8747

Bay Area Office
449 - 15th Street
Suite 401
Oakland, CA 94612
(510) 839-0811

## ទៅខាងមុខ

កូនសៀវភៅនេះបានរៀបចំឡើងដោយសមាគមសំរាប់ប្រជាពលរដ្ឋពិការនៃរដ្ឋកាលីហ្វ័រនីញ៉ា (ARC-C), អតីតមានឈ្មោះថា សមាគមកាលីហ្វ័រនីញ៉ាសំរាប់មនុស្សមានភាពពិការ (California Association for the Retarded - C.A.R) មុនបានផ្លាស់ប្តូរឈ្មោះកាលពីខែកុម្ភៈ ទី 5 ឆ្នាំ 1981 ។

ការស្រាវជ្រាវច្បាប់និងការវិនិច្ឆ័យនៅពេលបោះពុម្ពលើកដំបូងបានធ្វើឡើងដោយលោក Sterling L. Ross, Jr., អ្នកច្បាប់, ស្របតាមទំនាក់ទំនងជាមួយសមាគម ARC-C ។ លោក Ross បានធ្វើការជួយដល់ក្រុមគ្រួសារមួយចំនួនធំដែលមានភាពពិការជិត 20 ឆ្នាំកន្លងមកនៅខោនធី សាន់ ប្រ្វាន់ស៊ីស្កូ និងខោនធី ម៉ារិន ។ លោក Ross ជាបុគ្គលិកអ្នកច្បាប់ដែលចេញធ្វើការដំបូងគេឲ្យសមាគម C.A.R ហើយបានចូលបំរើពីឆ្នាំ 1971 ដល់ឆ្នាំ 1973 ។

កូនសៀវភៅនេះរៀបរាងឡើងដើម្បីបង្ហាញពីបញ្ហា**ច្បាប់**មានភាពស្មុកស្មាញក្នុងអភិរក្សភាព (អ្នកការពារទ្រព្យសម្បត្តិ) និងអភិរក្សមានកំរិត, ហើយនិងការត្រូវការភារៈគ្រប់គ្រងទ្រព្យពិសេស, ហើយក៏បានធ្វើឡើងដោយសរសេរជាភាសាដែលអាចងាយយល់ស្រួលពី "ប្រជាពលរដ្ឋទូទៅក្នុងរដ្ឋកាលីហ្វ័រនីញ៉ា"។ ពីព្រោះទទួលទូទៅបានធ្វើបង្កើតកូនសៀវភៅនេះឡើង បានប្រើពាក្យពេចន៍ដែលសង្កត់ទៅលើប្រជាពលរដ្ឋដែលមាន "បញ្ហាខួរក្បាល" ហើយនិង "កើតមានភាពពិការ" ហើយ "ឪពុកម្តាយ" របស់គេ; ក៏ប៉ុន្តែ ផ្នែកខាងច្បាប់តែងតែមានអត្ថន័យទូលំទូលាយ។ ការផ្លាស់ប្តូរច្បាប់ចាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 1996 បានដាក់បញ្ចូលទៅក្នុងសម្ភារៈទាំងអស់នេះ។

## សារព័ន៌ស័ព្ទច្បាប់

**អ្នកទទួលផល។** បុគ្គល់ឬក្រុមហ៊ុនដែលទទួលផលពីជំនួញ ឧទាហរណ៍ អ្នកមានឈ្មោះទទួលប្រាក់ធានាជីវិត, អ្នកទទួលប្រាក់កាស, អ្នកទទួលមត៌ក។

**លិខិតកែមត៌កសាសន៍។** ការបន្ថែមទៅនិងមត៌កសាសន៍។ លិខិតកែមត៌កសាសន៍ គឺជាឯកសារដោយឡែក។ ជាលិខិតចុះហត្ថលេខាដូចកេរ្តិ៍មរតកដែរ។ លិខិតកែមត៌កសាសន៍នេះ អាចកែប្រែ ឬ លុបចោលគ្រប់ពេលបាន។

**អភិរក្សជនទទួល។** មនុស្សនៅក្រោមអភិរក្សភាព ដែលគេចាត់តាំងឲ្យមានអភិរក្សជនមើលថែរក្សាទ្រព្យសម្បត្តិអោយ។

**កុងត្រា។** សេចក្តីយល់ព្រមតាមច្បាប់។

**ការផ្ញើទុកប្រាក់កាសដោយឡែក។** ភារៈគ្រប់គ្រងប្រាក់កាសសំរាប់ផ្តល់ឲ្យអ្នកទទួលផល ដែលមានក្នុងលក្ខន្តិកៈធ្វើឲ្យអ្នកទទួលផលផុតពីការទាមទាររបស់ឥណទាយក។

**ពន្ធទ្រព្យ (សហព័ន្ធ)។** ពន្ធស្លាប់ដែលបានដាក់ដោយរដ្ឋាភិបាលលើការផ្ទេរទ្រព្យសម្បត្តិរបស់អ្នកស្លាប់។ ពន្ធនេះភាគច្រើនបង់ដោយអ្នកប្រតិបត្តិ។

**អ្នកទទួលមរតក។** មនុស្សដែលមានឈ្មោះទទួលទ្រព្យតាមច្បាប់របស់រដ្ឋ។

**ពន្ធមត៌កសម្បត្តិ។** ពន្ធស្លាប់ដែលដាក់ទៅលើក្រុមគ្រួសារដែលទទួលទ្រព្យសម្បត្តិ។ ពន្ធមត៌កសម្បត្តិ របស់រដ្ឋកាលីហ្វ័រនីញ៉ាបានលុបចោលច្បាប់នេះតាមលក្ខន្តិកៈច្បាប់ដំបូងនៅខែមិថុនា ឆ្នាំ 1982 ។

**អិនធ័រ វីវ៉ូ ភារៈគ្រប់គ្រង។** ភារៈគ្រប់គ្រងបានបង្កើតឡើង "ចន្លោះការរស់នៅ" ក៏បានហៅថា "ភារៈគ្រប់គ្រងរស់នៅ"។ អ្នកធានា (អ្នកផ្តល់ការថែរក្សា) ជាមនុស្សរស់។ ប្រៀបធៀបនេះទៅនិងភារៈគ្រប់គ្រងមត៌កសាសន៍។

**ភារៈគ្រប់គ្រងមិនអាចបដិសេធបាន។** ជាភារៈគ្រប់គ្រងមួយដែលលក្ខន្តិកៈនិងខដែលមានចែកមិន អាចកែប្រែបាន ឬដកហូតមកវិញ។ នៅក្រោមកាលៈទេសៈមានកំរិតខ្លះ តុលាការអាចធ្វើការកែប្រែមានកំរិតបានខ្លះ។

ចំចាត់តាំងអ្នកមើលខុសត្រូវកណ្តាលពិនិត្យមើលតម្លៃនៃទ្រព្យនិងសម្ភារៈហើយនិងតម្លៃប៉ាន់ ត្រូវតែដាក់ពាក្យមកតុលាការ។ (អ្នកតំណាងមិនមែនអ្នកពិនិត្យកណ្តាល ពិនិត្យមើលតម្លៃ "វត្ថុជាប្រាក់សុទ្ធ" ហើយមេធាវីរបស់លោកអ្នកនឹងណែនាំប្រាប់លោកអ្នកអំពីរបៀបធ្វើ)។

5. ក្រោយពីលោកអ្នកបានទទួលសិទ្ធជាអ្នកតំណាងទ្រព្យលោកអ្នកត្រូវតែដាក់កុងបង្ហាញរាល់ឆ្នាំ (ឬក៏ជាញឹកញ៉ាប់តាមតុលាការបញ្ជា) ពីទ្រព្យសម្បត្តិដែលលោកអ្នកបានទទួលក្នុងរយៈពេលឆ្នាំនោះ ហើយអ្វីដែលលោកអ្នកចំណាយ។ លោកអ្នកត្រូវពន្យល់អធិប្បាយក្បោះក្បាយអ្វីដែលនៅសល់ ក្រោយពីបង់ចំណាយនោះហើយ ("សំណល់នៅលើដៃ")។

6. លោកអ្នកត្រូវសុំការអនុញ្ញាតពីតុលាការដើម្បីលក់, ចាកចេញ, ប្រាក់ខ្ចី ឬទុននៃទ្រព្យនោះ។ ក្រដាសដាក់សុំការអនុញ្ញាតគឺជាទូទៅធ្វើឡើងដោយមេធាវីរបស់លោកអ្នក។

ជាការសំខាន់ណាស់ដែលលោកអ្នកត្រូវសហាការជាមួយមេធាវីរបស់លោកអ្នកគ្រប់វេលា ធ្វើដូច្នេះ មេធាវីអាចជួយលោកអ្នកទុកដាក់បន្ទុកដែលប្រគល់ឲ្យលោកអ្នកនេះបានល្អប្រសើ។ នៅពេលណា លោកអ្នកមានការមន្ទិលសង្ស័យ ចូរទាក់ទងមកមេធាវីភ្លាម,

SUPERVISING PROBATE JUDGE
Courtesy ... LONG BEACH REPORTER
P.O. Box 4278
3010 E. Anaheim St.
Long Beach, CA 90804
(213) 432-5207 ឬ (213) 438-5641



បញ្ជីរាយសារព័នស័ព្ទច្បាប់ដែលបានប្រើច្រើននៅក្នុងផ្នែកនៃច្បាប់បានដាក់បញ្ចូល ចាប់ផ្តើមនៅទំព័រខាងខ្នង។ សូមពិនិត្យមើលមុននិងចាប់ផ្តើមអានកូនសៀវភៅ ធ្វើដូច្នេះវាអាចជាជំនួយជួយជាគោល។

គោលច្បាប់ហើយនិងការពន្យល់ក្បោះក្បាយបានដាក់បញ្ចូលជាបំណង។ អ្នកអាចត្រូវចង់ចាំថា កូនសៀវភៅមានគោលបំណងលើកយកបញ្ហាហើយនិងសំណួរដែលត្រូវគិតមើលនៅពេលអ្នកណាមួយពិនិត្យរកមើលភាពទំនងនៃអភិរក្សភាព, អភិរក្សភាពក៏រិត, មត៌កសាសន៍ ឬភារៈគ្រប់គ្រងទ្រព្យ។

បើសិនជាមានសំណួរអ្វីអំពីការអនុវត្តមាតិការនៃកូនសៀវភៅដល់សកម្មភាពបុគ្គលម្នាក់ៗ អ្នកអាច គួរតែស្នើសុំការទូរន្មានពីមេធាវី។

## ផ្នែកទី 1

## អភិរក្សភាព, អាណាព្យាបាលភាពហើយនិងអភិរក្សភាពកំរិត

## អត្ថន័យនៃសារព័នស័ព្ទ

### តើអភិរក្សភាពជាអ្វីដែរ ?

ពាក្យអភិរក្សភាព គឺជារឿងក្តីតាមច្បាប់ក្នុងករណីបុគ្គល់ ឬ ភ្នាក់ងារ (ដែលមានឈ្មោះថា "អ្នកផ្តល់អភិរក្ស") ដែលបានចាត់តាំងឡើងដោយតុលាការ ដើម្បីទទួលបន្ទុកមើលខុសត្រូវមនុស្សដែលត្រូវការជំនួយក្នុងការធ្វើសកម្មភាពរស់នៅរាល់ថ្ងៃ ("អ្នកទទួលអភិរក្ស")។ អ្នកផ្តល់អភិរក្សត្រូវតែមានសេចក្តីពិតប្រាកដថា អ្នកទទួលអភិរក្សបានចិញ្ចឹមថែរក្សាត្រឹមត្រូវ, មានសំលៀកបំពាក់ត្រឹមត្រូវនិងកន្លែងរស់នៅស្រួល។ អ្នកផ្តល់អភិរក្សការពារទ្រព្យ គឺទទួលបន្ទុកចាត់ចែងប្រាក់កាសរបស់អ្នកទទួលអភិរក្ស ហើយនិងទ្រព្យសម្បត្តិផ្សេងៗ។ បុគ្គល់ម្នាក់អាចធ្វើជា**អ្នកផ្តល់អភិរក្សការពារមនុស្សនោះ ឬអ្នកផ្តល់អភិរក្សការពារមើលទ្រព្យ** ឬក៏ទទួលភារៈកិច្ចទាំងពីរ។ អ្នកផ្តល់អភិរក្ស គឺតម្រង់ទៅមនុស្សពេញវ័យ ឧទាហរណ៍ មនុស្សមានអាយុ (18) ឆ្នាំ ឬមានអាយុចាស់ជាងនេះ។

មុនតុលាការនឹងបញ្ចេញឲ្យដាក់ពាក្យតវ៉ាសំរាប់ណាត់ជួបុគ្គល់អ្នកផ្តល់អភិរក្សផ្ទាល់អ្នកទទួលអភិរក្សត្រូវតែបង្ហាញថា ខ្លួនមិនអាចថែរក្សាខ្លួនឯងបានត្រឹមត្រូវសំរាប់សុខភាព, ម្ហូបអាហារ, ខោអាវ ឬជំរក។ អ្នកអភិរក្សទទួលមើលខុសត្រូវទ្រព្យប្រហែលជាអាចតាំងឡើងឲ្យមនុស្សដែលភាគច្រើនមិនអាចទុកដាក់ប្រាក់កាសខ្លួនឯង ឬ ខ្លាចនិងការប្រទ្បំ ឬ ការរំលោភត្រឹមត្រូវ។



ធនាគារសំរាប់ដាក់ប្រាក់ ត្រូវដាក់ឈ្មោះទ្រព្យនិងភារៈគ្រប់គ្រង់ (ខ្លួនលោកអ្នក)។ សន្តិសុខទ្រព្យ ត្រូវតែដាក់ក្នុងឈ្មោះទ្រព្យផងដែរ។ ក្នុងអាណាព្យាបាលភាពចំពោះក្មេងមានការគ្រប់គ្រង់ច្រើន លោកអ្នកត្រូវរក្សាទុកបញ្ជីកត់ចេញចូលកុងធនាគារនៃទ្រព្យសម្បត្តិទាំងអស់ដែលជារបស់មនុស្ស ដែលគេគ្រប់គ្រងនិមួយៗនោះ ហើយនិងប្រកាន់ដៃទាំងអស់ ហើយនិងប្រាក់សងពីកុងធនាគារនិមួយៗ។ អ្នកធានាប្រាក់បង់ធានាទ្រព្យសម្បត្តិសំរាប់ការបាត់បង់ ប្រហែលជាតម្រូវឲ្យអ្នកតំណាង ឬមេធាវីរបស់លោកអ្នក ធ្វើជាមួយលោកអ្នក ចុះហត្ថលេខាលើសែក ឬបទដកហូតប្រាក់ចេញពីធនាគារ។

2. ឪពុកម្តាយមិនអាចមានសិទ្ធប្រើទ្រព្យរបស់កូននៅវ័យក្មេងដើម្បីយកមកជួយឧបត្ថម្ភកូននោះនៅវ័យនោះឡើយ។ តុលាការប្រហែលជាអនុញ្ញាតិឲ្យលោកអ្នកដកហូតប្រាក់កាសខ្លះពីថវិកានោះក្រោយពីសវនាការលោកអ្នកទាមទាសិន ហើយលោកអ្នកក៏មិនអាចប្រើប្រាសលុយដល់តែតុលា ការបញ្ចេញបទបញ្ជា។ ជាអ្នកតំណាងលោកអ្នកមិនត្រូវប្រើប្រាសលុយកាក់នៃទ្រព្យ រហូតដល់ លោកអ្នកបានទទួលការអនុញ្ញាតពីតុលាការសុំពលកម្មជាមុនសិន។ បើសិនជាលោកអ្នកមិនបានសុំ ការអនុញ្ញាត គេនឹងផាកលោកអ្នក ឧទាហរណ៍ លោកអ្នកត្រូវសងលុយនោះមកវិញពីថវិកាខ្លួនឯង។ (មានការលើកលែងខ្លះ ដូចជាការយល់ព្រមទាមទាររបស់អ្នកឲ្យលុយខ្ចី ឬថ្លៃបង់ពន្ធ។ ក៏ប៉ុន្តែ លោកអ្នកគួរទាក់ទងមកមេធាវីមុននឹងបង់ថ្លៃទាំងនេះ)។

3. លោកអ្នកអាចសុំដែលលោកអ្នកបានបង់ថ្លៃតុលាការហើយនិងថ្លៃបង់ប្រាក់បង់ធានារបស់លោកអ្នក។ លោកអ្នកប្រហែលជាមិនចាំបង់ថ្លៃមេធាវី ឬខ្លួនឯងដោយគ្មានបទបញ្ជាពីតុលាការមុនសិន។

4. ក្នុងរយៈពេល 3 ខែ ក្រោយពីគេបានចាត់តាំងលោកអ្នក លោកអ្នកត្រូវតែដាក់ពាក្យទៅតុលាការ អំពីប្រាក់កាសនិងទ្រព្យសម្បត្តិផ្សេងៗទាំងអស់ដែលថែរក្សាដោយលោកអ្នក។ លោកអ្នកត្រូវតែរៀប

គំរោងកប់ឬតំបែហរសពគួរមានបញ្ជាក់នៅក្នុងឯកសារ, ជាទូទៅដាក់ឈ្មោះថា "ក្បួនសំរាប់ឲ្យអ្នកប្រតិបត្តិរបស់ខ្ញុំ" ហើយរក្សាទុកឯកសារនៅក្នុងប្រអប់សន្តិសុខ។ នៅក្នុងឯកសារនោះ គួរតែមានរួមចូលក្បួនទាក់ទងការរៀបចំសំរាប់មើលថែរក្សាបុគ្គលដែលនៅរស់ក្រោយពីឪពុកម្តាយស្លាប់ទៅ។ ក្បួនប្រាប់ពីការទាក់ទងទៅថ្នាំពេទ្យ ហើយនិងការដាក់កន្លែងឲ្យរស់នៅ។

**សំគាល់ : តទៅនេះ គឺជាឧទាហរណ៍នៃក្បួនដល់តំណាងទ្រព្យដែលបានប្រើក្នុងតុលាការរដ្ឋកាលី ហ្វ័រនីញ៉ា។ មនុស្សដែលមានចិត្តលើរឿងនេះ គួរតែទាក់ទងមកតុលាការក្នុងតំបន់របស់ខ្លួន ហើយ/ឬអ្នកស៊ើបអង្កេតសំរាប់កន្លែងជាក់លាក់។**

## តុលាការសុពលកម្ម

## តុលាការជាន់ខ្ពស់

## ក្បួនប្រាប់ទូទៅដល់អ្នកតំណាងទ្រព្យ

(អ្នកថែរក្សាទ្រព្យ, អាណាព្យាបាល, អ្នកចាត់ចែង ឬអ្នកប្រតិបត្តិ) (មេធាវីបានស្នើសុំឲ្យបញ្ជូនទៅឲ្យអ្នកតំណាង)

អ្នកត្រូវបានតុលាការជ្រើសរើសឲ្យធ្វើអ្នកតំណាងទ្រព្យដោយតុលាការនេះ។ នៅពេលបានទទួលធ្វើ ជាតំណាង អ្នកក្លាយទៅជាភ្នាក់ងារនៃតុលាការហើយទទួលមុខងារនិងតម្រូវការខ្លះ។ មេធាវីគឺជាឲ្យឪវាទល្អដល់លោកអ្នកចំពោះរឿងរ៉ាវទាំងនេះ ក៏ប៉ុន្តែលោកអ្នកតែយល់ច្បាស់លាស់ភារកិច្ចដូចតទៅនេះ :

1. លោកអ្នកទុកដាក់ប្រាក់កាសនិងទ្រព្យសម្បត្តិនេះដោយឡែកពីទ្រព្យសម្បត្តិរបស់លោកអ្នកផ្ទាល់ ហើយមិនត្រូវលាយឡំគ្នាជាមួយទ្រព្យសម្បត្តិរបស់លោកអ្នកឡើយ។ នៅពេលលោកអ្នកបើកកុង



## តើអាណាព្យាបាលភាពជាអ្វី ?

តាំងពីខែ មករា ឆ្នាំ 1981 ពាក្យអ្នកអាណាព្យាបាលគឺ ប្រើតម្រង់ទៅលើក្មេងមិនទាន់ពេញវ័យ**ប៉ុណ្ណោះ** ឧទាហរណ៍ មនុស្សដែលមានអាយុក្រោម ដប់ប្រាំបី (18) ឆ្នាំ។ គោលបំណងរបស់អ្នកអាណាព្យាបាលភាព គឺដើម្បីផ្តល់ភាពការពារឲ្យក្មេងដែលគ្មានឪពុកម្តាយ។

មុនឆ្នាំ 1981 ពាក្យអាណាព្យាបាលគឺតម្រង់ទៅលើមនុស្សពេញវ័យដែលពិការ ហើយមានន័យស្រដៀងនិងពាក្យអភិរក្សភាព (អ្នកការពារ) ដែរ។ អាណាព្យាបាលសំរាប់ឲ្យមនុស្សពិការបានចាប់ផ្តើមនៅខែ មករា ទី 1 ឆ្នាំ 1981, ក្លាយទៅជាអភិរក្សភាព**ឯងៗតែម្តង** បើសិនជាអាណាព្យាបាលមានអាយុលើសពី 18 ឆ្នាំ នៅខែមករា ទី 1 ឆ្នាំ 1981 ។ ការផ្លាស់ប្តូរក្នុងអាណាព្យាបាលជាផ្នែក មួយនៃការកែប្រែឡើងវិញនៃច្បាប់អាណាព្យាបាលភាពរដ្ឋកាលីហ្វ័រនីញ៉ា ហើយនិងច្បាប់អភិរក្ស ភាព។

តាំងពីអភិរក្សភាពនិងអភិរក្សភាពមានកំរិតជាទូទៅគឺសំរាប់តែការពាររៀបចំច្បាប់ទម្លាប់សំរាប់ឲ្យ មនុស្សពិការពេញវ័យក្រោយឆ្នាំ 1981, កូនសៀវភៅនេះនឹងមិនបូកបញ្ចូលការពិភាក្សានៃអាណាព្យាបាលភាពឡើយ។

[1] "ការមានកើតភាពពិការ" មនន័យថា ភាពពិការដែលមានកើតឡើងមុនបុគ្គលនោះមានអាយុ 18 ឆ្នាំ, ជាបន្ត ឬអាចសន្និដ្ឋានមានបន្ត, គ្មានទីកំណត់, ហើយជាភាពពិការធ្ងន់ចំពោះបុគ្គលនោះ។ សារព័ន៍សព្ទនេះគួរតែរាប់ទាំងការមានវិកលចរិត

## តើអភិរក្សភាពមានកំរិតជាអ្វី ?

អភិរក្សភាពកំរិត គឺជាតំរង់នៃអភិរក្សភាពទូទៅ ហើយតម្រង់ទៅលើមនុស្សពេញវ័យប៉ុណ្ណោះ ដែល "កើតមានភាពពិការ" ដែលបញ្ជាក់នៅក្នុងច្បាប់រដ្ឋ,[1] ខ្ញុំហើយនិងអ្នកណា, ឬប្រហែលជាអាច, អ្នកទទួលកិច្ចបំរើនៃមណ្ឌលក្នុងតំបន់កាលីហ្វ័រនីញ៉ាដែលបំរើមនុស្សកើតមានភាពពិការ។ ការរៀបចំការពារនេះ គឺមាន "កំរិត" ពីព្រោះតែមនុស្សពេញវ័យដែលកើតមានភាពពិការមានសមត្ថភាពថែរក្សាខ្លួនឯង ហើយ/ឬទុកដាក់ប្រាក់កាស់តាមសមត្ថភាពខ្លួនធ្វើទៅបាន ដូចបានថែងពីតុលាការ។ អភិរក្សភាពកំរិតបានប្រើដើម្បីលើកស្ទួយ ហើយនិងការពារការស្មើនៅរបស់បុគ្គល់ ហើយរៀបឡើងសំរាប់លើកទឹកចិត្តឲ្យបុគ្គល់នោះអាចថែរក្សាខ្លួន ហើយឯករាជ។

## សំណួរអំពីអភិរក្សភាព

### ហេតុយ៉ាងម៉េចបានជាអភិរក្ស (អ្នកការពារ) សំខាន់ ?

បើសិនជាលោកអ្នកជាឪពុកម្តាយរបស់កូនមានអាយុ**ពេញវ័យ** ដែលកើតមានភាពពិការ, អភិរក្សភាពអាចផ្តល់ឲ្យលោកអ្នកនូវសិទ្ធពេញច្បាប់ពិគ្រោះអ្វីៗកូនបាន, ឬក៏ជាអ្នកថែទាំកូននោះ, បើមិនដូច្នេះទេ លោកអ្នកមិនអាចមានសិទ្ធធ្វើបែបនេះឡើយ។

ជាឪពុកម្តាយកូនក្មេង លោកអ្នកជាអាណាព្យាបាលធម្មជាតិ ហើយជាទូទៅមានអំណាចស្មើគ្នា ហើយនិងអាជ្ញាធរជាអ្នកអាណាព្យា

---

[1] ជម្ងឺខួរក្បាល និងជម្ងឺឡប់សតិ។ សារព័នស័ព្ទនេះក៏គួរតែរួមទាំងលក្ខណៈពិការដែលឃើញថាមានទាក់ទងទៅនិងជម្ងឺវិកលចារិត ឬតម្រូវឲ្យមានការព្យាបាលដែលប្រហាក់ប្រហែលនិងការព្យាបាលជម្ងឺខួរក្បាលចំពោះបុគ្គល់នោះ ប៉ុន្តែមិនគួរលក្ខណៈពិការខ្លួនប្រាណដែលកើតពីធម្មជាតិ។ (Welfare and Institutions Code 4512.)



មានបន្ទុកទៅមើលអ្នកទទួលការរក្សាផ្ទាល់ខ្លួន។ បើសិនជាគ្មានខ្វះសេចក្តីត្រូវការ អ្នកថែរក្សាទ្រព្យត្រូវតែប្រាប់មកអ្នកមានភារះគ្រប់គ្រងទ្រព្យដែលជាអ្នកមានបន្ទុក រៀបទុកដាក់លុយប្រើប្រាសសមស្របជាមួយខដែលមានចែកក្នុងលក្ខន្តិកៈយល់ព្រម។ ការប្រព្រឹត្តទៅមិនបានត្រឹមត្រូវរបស់អ្នកមានភារៈគ្រប់គ្រងនឹងឲ្យដឹងមកដល់អ្នកថែរក្សាទ្រព្យដូចនិងការប្រព្រឹត្តមិនបានត្រឹមត្រូវរបស់អ្នកថែរក្សាទ្រព្យដូចគ្នាដែរ។

នៅពេលណាឪពុកម្តាយមានទ្រព្យសម្បត្តិមានតម្លៃច្រើនប្រភេទ ឬក៏ឪពុកម្តាយនេះមានការជឿងជាក់ទៅលើមនុស្សម្នាក់បុគ្គល់ម្នាក់អាចទទួលបន្ទុកទាំងពីរនេះបាន។

### តើឲ្យឪពុកម្តាយរៀបចាត់តាំងអ្នកថែរក្សាទ្រព្យបានល្អនៅពេលគាត់មរណៈទៅនោះ ដោយរបៀបណា ?

ចំពោះកេរ្តិ៍មរតករបសគាត់ ឪពុកម្តាយគួររើសតាំងអ្នកថែរក្សាទ្រព្យនៅពេលគាត់ទាំងពីរបានចែក ឋានទៅ។ របៀបដាក់តាំងគឺដូចការប្ររព្ធធ្វើអភិរក្សភាពដំបូង ទោះជាឪពុកម្តាយបានចាត់តាំងអ្នកថែរក្សាទ្រព្យជំនួសគាត់ក៏ដោយ។

ការចាត់តាំងអ្នកថែរក្សាទ្រព្យអាចធ្វើឡើងបានជាងតាមកេរ្តិ៍មរតក។ ឯកសារបញ្ជាក់គឺពេញច្បាប់ចាត់តាំង បើសិនជាបង្ហាញនូវយល់ស្របនិងចុះហត្ថលេខាដោយឪពុកម្តាយនោះ។

### តើមានការរៀបចំជាងកេរ្តិ៍មរតកដែលឪពុកម្តាយគួរគិតមើលសំរាប់ឲ្យកូនមានភាពពិការឬទេ ?

បាន។ នៅពេលណាឪពុកម្តាយធ្វើពិធីរៀបចំសំរាប់តំហែសពនៅពេលគាត់ស្លាប់ ឬពិធីកប់គាត់ក៏គួរគិតរៀបចំទុកដាក់ឲ្យកូនផងដែរ។

ធំគឺយោងទៅលើការស្ម័គ្រចិត្តធ្វើនៃធនាគារទទួលបន្ទុកហើយនិងបែងចែកផ្នែកទទួលខុសត្រូវរវាងសហគ្រប់គ្រង។

## តើអ្វីច្រើនជាខុសក្នុងការរៀបចំប្រាក់កាសសំរាប់មនុស្សដែលមានកើតភាពពិការនោះ ?

1. រួមចូលកូនដែលមានកើតភាពពិការជាគោល ឬអ្នកទទួលផលប្រយោជន៍បន្ទាប់ពីក្រុមហ៊ុនធានាជីវិត។
2. ប្រគល់អ្នកថែរក្សាទ្រព្យ ជាជាងភារៈគ្រប់គ្រង ដើម្បីរៀបចំទុកដាក់ទ្រព្យសម្បត្តិដែលទុកឲ្យពី ឪពុកម្តាយដល់កូនដែលមានកើតភាពពិការ។
3. ចាត់តាំងអ្នកថែរក្សាទ្រព្យសម្បត្តិអោយមនុស្សដែលមានកើតភាពពិការនៅពេលទ្រព្យដែលអ្នកទទួលការរក្សាគឺជំនួយរបស់រដ្ឋប៉ុណ្ណោះ។

## តើអាចឲ្យអ្នកទទួលការគ្រប់គ្រងមានសិទ្ធិយល់ព្រមដល់ការព្យាបាលសុខភាពលើអ្នកទទួលផលប្រយោជន៍ ហើយនិងរៀបចំទុកដាក់រឿងរ៉ាវក្រៅពីលុយកាក់ដែរឬទេ ?

ទេ។ អំណាយរបស់អ្នកទទួលការគ្រប់គ្រងគឺមានកំរិតដល់ការរៀបចំទុកដាក់លុយកាក់។ អ្នកថែរក្សាទ្រព្យត្រូវតែចាត់តាំងឲ្យមាននៅពេលឪពុកម្តាយស្លាប់បើសិនជាមនុស្សត្រូវការការថែទាំជាចាំបាច់។

## តើគួរឲ្យអ្នកទទួលការគ្រប់គ្រងហើយនិងអ្នកថែរក្សាទ្រព្យរបស់មនុស្សនោះជាបុគ្គលដូចគ្នាទេ ?

តាមការចង់នោះ គឺអត់ទេ។ ការបែកចែកប្រាក់កាសពីការត្រួតត្រាផ្ទាល់ខ្លួនបង្កើតប្រព័ន្ធការពិនិត្យ និងថ្លឹងថ្លែង។ អ្នកថែរក្សាទ្រព្យ



បាលដែលតុលាការបានចាត់អោយ។ នៅពេលកូនរបស់លោកអ្នកមានអាយុធំដឹងក្តី, កូននេះក្លាយទៅជារួចផុតពីការត្រួតពិនិត្យពីឪពុកម្តាយ។ ច្បាប់**សន្មត់**ថា បុគ្គល់នោះ ដោយមិនគិតពីលក្ខណៈភាពពិការ គឺមានសិទ្ធប្រព្រឹត្តបានដូចមនុស្សពេញវ័យ។

នៅពេលណាការកើតមានភាពពិការ ឬភាពវិកលចារិតកំរិតសមត្ថភាពមនុស្សនោះបញ្ចេញសិទ្ធរបស់ខ្លួន មនុស្សនេះត្រូវការអ្នកដទៃណាម្នាក់ទទួលខុសត្រូវលើសិទ្ធណាមួយអោយ។ អភិរក្សភាពអាចធ្វើជាពុកម្តាយប្រព្រឹត្តអ្វីជំនួសបុគ្គលដែលត្រូវមានការពិនិត្យមើលប្រចាំពេលពីតុលាការ។

អភិរក្សភាពគឺសំខាន់ណាស់ នៅពេលកិច្ចយល់ព្រមបានតម្រូវអោយធ្វើអំពើពិតប្រាកដណាមួយ, ហើយមនុស្សដែលវិកលចារិត ឬក៏ការកើតមានភាពពិការផ្សេងៗទៀត ដែលមិនអាចឲ្យបាន។ ឧទាហរណ៍ "កិច្ចបញ្ជាក់យល់ព្រម" នៃអ្នកជម្ងឺបានត្រូវឲ្យមានមុននិងមានការវះកាត់ធ្វើប្រព្រឹត្តទៅបាន។ បើសិនជាអ្នកជម្ងឺនោះមាន**វ័យក្មេង** និងមានវិកលចារិត ឬក៏កើតមានភាពពិការផ្សេងៗទៀត វេជ្ជបណ្ឌិតនិងមន្ទីរពេទ្យជាទូទៅនឹងទទួលយកកិច្ចយល់ព្រមពីឪពុកម្តាយ។ តែបើសិនជាអ្នកជម្ងឺ**ពេញវ័យ**និងមានរោគវិកលចារិត ឬក៏មានកើតភាពពិការផ្សេងៗទៀត កិច្ចយល់ព្រមពីឪពុកម្តាយជាញឹកញ៉ាប់ គេ**មិន**ទទួលយកឡើយ លុះត្រាឪពុកម្តាយនោះជាអ្នកការពារកូនមានជម្ងឺនោះ។ ដោយគ្មានការស្នើសុំអភិរក្សភាពទេ ឪពុកម្តាយអាចដាក់ពាក្យទៅតុលាការស្នើសុំការអនុញ្ញាត ដើម្បីឲ្យកិច្ចយល់ព្រមដល់ការព្យាបាលសុខភាពនោះ។ បន្ថែមទៅទៀត ក្នុងសភាពការខ្លះ អ្នកចាត់ចែងនៅមណ្ឌលក្នុងតំបន់ប្រហែលជាអាចផ្តល់កិច្ចយល់ព្រមដល់ការព្យាបាលសុខភាពសំរាប់ឲ្យអ្នកទទួលកិច្ចបំរើពីមណ្ឌលក្នុងតំបន់នោះ។

អំណាចនិងបន្ទុករបស់អ្នកការពារនឹងមានចែងក្នុងបទបញ្ជារនៃការដាក់ណាត់និងលក្ខន្តិកៈច្បាប់។ ការយល់ច្បាស់លាស់នៃអំណាចនិងបន្ទុក គឺសំខាន់ណាស់នៅពេលប្រស្រ័យទាក់ទងជាមួយនិងភ្នាក់ងារសាធារណៈ ហើយនិងអ្នកចាត់ចែងមណ្ឌលនិងកម្មវិធីពេលថ្ងៃ។ ឧបម៉ាថា ឪពុកម្តាយដែលជាអ្នកអភិរក្សត្រូវតែបានទទួលការបញ្ជាក់និងការចង់ផ្លាស់ប្តូរស្របច្បាប់ក្នុងកន្លែងរស់នៅ, ការអប់រំ ឬកិច្ចបំរើជួយឡើងវិញ។

## តើអាចអោយខ្ញុំបាន់ស្មានមើល បើសិនជាអភិរក្សភាពត្រូវការជាចាំបាច់នោះ ?

ការសម្រេចគួរ ឬមិនគួរសុំអភិរក្សភាពនឹងសំរេចទៅលើគោលលក្ខណនៃករណីសំណុំរឿងបុគ្គលម្នាក់ៗ លោកអ្នកស្នើសុំការទូន្មានពីទីប្រឹក្សា។ សំណួរខ្លះ ដែលលោកអ្នកគួរយកមកសាកសួរ ដើម្បីស្មង់មើលបើសិនជាអភិរក្សភាពត្រូវតែមានជាចាំបាច់នោះ :

1. តើការសម្រេចណាដែលប៉ះពាល់ដល់ប្រាក់កាស់សំរាប់រស់នៅរបស់បុគ្គលដែលកើតមានភាពពិការដែលធ្វើឲ្យបុគ្គលនោះទុកដាក់ខ្លួនឯងបាន ? តើអាចឲ្យការសម្រេចនេះធ្វើឡើងតាមមធ្យោបាយខុសពីការបង្កើតឲ្យមានអភិរក្សភាពបានទេ ? ឧទាហរណ៍ បើសិនជាប្រាក់ចំណូលរបស់បុគ្គលនោះ មានតែប្រាក់ SSI ទេ ការចាត់ចែងលុយកាក់នេះ អាចប្រព្រឹត្តធ្វើទៅតាមតំណាងអ្នកទទួលសែក។

2. ចុះមនុស្សពេញវ័យមានជម្ងឺរិកលចារិត ឬកើតមានភាពពិការអាចចាត់ចែងទុកដាក់ខ្លួនឯងបានល្អ សំរាប់សុខភាព, ម្ហូបអាហារ, ខោអាវ ឬ ជំរកនោះ ?



អ្នកថែរក្សាទ្រព្យត្រូវតែមានចាត់តាំងឡើង អ្នកនោះនិងផេទ្រព្យសម្បត្តិទៅឲ្យអ្នកទទួលភារៈគ្រប់គ្រងទ្រព្យដែលរក្សាទុកស្របតាមសេចក្តីយល់ព្រម។

ជាញឹកញ៉ាប់ ឪពុកម្តាយបានទទួលការណែនាំឲ្យបង្កើតភារៈគ្រប់គ្រងដែលពេលឪពុកម្តាយនៅរស់នៅឡើយ (ភារៈគ្រប់គ្រងទ្រព្យនៅពេលរស់រានមានជីវិតនៅឡើយ) សំរាប់ខ្លួនរបស់គេ ដើម្បីចៀសជាងសុពលកម្មនិងបន្ថយការចំណាយ។ ភារៈគ្រប់គ្រងត្រូវការពិសេសគឺស្រួលដាក់បញ្ចូលទៅក្នុងគំរោងនេះ ហើយជាទូទៅក្លាយភារៈគ្រប់គ្រងស្របច្បាប់នៅពេលប្តីឬប្រពន្ធស្លាប់។

## តើអ្នកណាគួរឈរធ្វើអ្នកទទួលទ្រព្យពីភារៈគ្រប់គ្រងត្រូវការពិសេសនេះ ?

មនុស្សធម្មតា ឬធនាគារអាចធ្វើជាអ្នកថែរក្សាទ្រព្យ។ ក្នុងកាលៈទេសៈខ្លះ សមាគមន៍អាចធ្វើជាអ្នកគ្រប់គ្រងទ្រព្យបាន។ [2]

ពីព្រោះតែអ្នកគ្រប់គ្រងជាក្រុមហ៊ុន ដូចជាធនាគារផាកកំរៃប្រចាំឆ្នាំយោងទៅលើភាគរយនៃទ្រព្យ ដែលមាននៅក្នុងភារៈគ្រប់គ្រងជាទូទៅសមាជិកក្រុមគ្រួសារ ឬមិត្តភក្តិជិតដិតធ្វើជាអ្នកគ្រប់គ្រងទ្រព្យ។ ក៏ប៉ុន្តែ គួរឲ្យដឹងដែលថា អ្នកគ្រប់គ្រងទ្រព្យប្រហែលជាចង់បានឈ្នួលក្នុងការទទួលបនកនេះ។ បុគ្គល់ធ្វើជាអ្នកទទួលគ្រប់គ្រងប្រហែលជាមានការជិតស្និតក្នុងសកម្មភាពរាល់ថ្ងៃនៃអ្នកទទួលផលប្រយោជន៍។

ម្យ៉ាងវិញទៀត ធនាគារ និងក្រុមហ៊ុនជាអ្នកគ្រប់គ្រងទ្រព្យច្រើនផ្តល់នូវការពិសោធន៍ពូកែជាងក្នុងរៀបចំទុកដាក់ប្រាក់កាស ហើយនិងកុងធនាគារហើយនិងរបាយការណ៍ពន្ធ។

ការជំនួសទីបី គឺយកអ្នកទាំងពីរ បុគ្គល់និងធនាគារសាមគ្គីគ្នាធ្វើជាសហអ្នកគ្រប់គ្រងទ្រព្យ។ ការបានសម្រេចនៃសហគ្រប់គ្រងទ្រព្យ

បញ្ចេញប្រាក់ឲ្យវិញ ចំពោះការកាត់ភារៈគ្រប់គ្រងសំរាប់ម៉េឌី-ខាលនៅពេលភារៈគ្រប់គ្រងនៅមាននៅឡើយ។

បទបញ្ជាភារៈគ្រប់គ្រងតុលាការគឺជាភារៈគ្រប់គ្រងធម្មតាបង្កើតឡើងសំរាប់ឲ្យមនុស្សមានភាពពិការ ដែលអ្នកបានទទួលជម្ងឺចិត្តពីការគ្រោះថ្នាក់ដល់ខ្លួនប្រាណ។ ច្បាប់រដ្ឋកាលីហ្វ័រនីញ៉ាអនុញ្ញាតឲ្យទុកដាក់នៅក្នុងកន្លែងត្រូវការភារៈគ្រប់គ្រងពិសេសសំរាប់មនុស្សប្តឹងមានភាពពិការបើសិនជាលក្ខណៈនោះត្រឹមត្រូវ។

បើសិនជាកូនរបស់លោកអ្នកនឹងបានទទួលប្រាក់ពីតុលាការចូរសួរមេធាវីអំពីការបង្កើតបទបញ្ជាតុលាការសំរាប់ភារៈគ្រប់គ្រងត្រូវការពិសេសដើម្បីទទួលនិងថែរក្សាប្រាក់កាសនោះ។

## តើនៅពេលណាគួរបង្កើតភារៈគ្រប់គ្រងត្រូវការពិសេស - នៅពេលឪពុកម្តាយនៅរស់ ឬក្រោយពេលគាត់មរណៈភាព ?

ជាទូទៅជាការលណាស់ត្រូវរងចាំដល់ឪពុកម្តាយចែកឋានសិនមុននិងទុកដាក់ភារៈគ្រប់គ្រងត្រូវការ ពិសេសនេះ។ បើសិនជាឪពុក ឬម្តាយនៅរស់នៅឡើយ ការបង្កើតភារៈគ្រប់គ្រងគឺមិនចាំបាច់ឲ្យមានទេព្រោះប្រាក់ជំនួយពីសាធារណៈនោះចេញមកពីឪពុកម្តាយដដែល។ រួមចូលទាំងភារៈគ្រប់គ្រងមត៌កសាសន៍របស់ឪពុកម្តាយទាំងពីរនាក់នឹងប្រើការបានដល់តែគាត់អស់ជីវិតទៅ នេះគឺជារៀបទូទៅ។

នៅក្នុងករណីខ្លះ ការបង្កើតភារៈគ្រប់គ្រងនៅពេលឪពុកម្តាយនៅរស់នៅឡើយជាការចាំបាច់ដែរ។ ឧទាហរណ៍ បើសិនជាយាយតាទុកប្រាក់កាសឲ្យកូនដែលមានកើតភាពពិការភារៈគ្រប់គ្រងបានធានា។

---

[2] បញ្ជាក់ទៅនិង Inland Counties Master Trust – អាចសុំព៌តមានពី Inland Counties Regional Center, តាមអាស័យដ្ឋាន P.O. Box 6127, San Bernardino, CA 92412.



3. តើវេជ្ជបណ្ឌិតប្រចាំគ្រួសារនឹងបន្តទទួលកិច្ចយល់ព្រមពីឪពុកម្តាយសំរាប់មើលសុខភាពឲ្យកូន ដែលមានជម្ងឺរិកលចារិត ឬកើតមានភាពពិការ ទោះបីតែកូននោះមានអាយុពេញវ័យហើយក៏ដោយ ?

4. តើមណ្ឌលក្នុងតំបន់បំរើមនុស្សដែលមានកើតភាពពិការបង្ហាញអភិរក្សឬ ?

## តើអភិរក្សភាពចាប់បង្កើតឡើងដោយរបៀបណា ?

អភិរក្សភាពប្រព្រឹត្តទៅបានដោយចាប់ផ្តើមបំពេញពាក្យប្តឹងទៅតុលាការសមលក្ខណៈណាមួយ, ជាទូទៅគឺតុលាការជាន់ខ្ពស់នៃខោនធីណាដែលអ្នកទទួលការពារនោះរស់នៅ។ លិខិតសវនាការ ហើយនិងក្រដាសពាក្យតវ៉ាចម្លងត្រូវតែផ្ញើឲ្យមនុស្សត្រឹមត្រូវនិងភ្នាក់ងារឲ្យបាន 15 ថ្ងៃមុននិងសវនាការ និងឯកសារ, ហៅថា ក្រដាសល្មើស, ត្រូវតែយកទៅអោយផ្ទាល់ដល់អ្នកទទួលការពារ។

អ្នកសុំការពារនោះ ត្រូវទៅចូលទៅស្តាប់សវនាការ បើមិនដូច្នេះទេ អ្នកនោះ (1) ចេញទៅក្រៅរដ្ឋ នៅពេលគេហៅ, (2) បញ្ជាក់ពីមន្ទីរ**ព្យាបាល**មិនអាចធ្វើទៅបាន, (3) មិនចង់មកចូលរួម ហើយក៏មិនប្រឆាំងនិងការតវ៉ានោះដែរ។ គួរឬមិនគួរអ្នកសុំការពារ ហើយអ្វីផ្សេងៗទៀត ត្រូវតែប្រាប់ឲ្យគេបានដឹងលក្ខណៈការប្រព្រឹត្តនោះ ហើយសួរមើលបើបុគ្គលនោះអាចមកចូលរួមក្នុងសវនាការ, មានគោលបំណងប្រឆាំងនិងអភិរក្សភាព, ប្រឆាំនិងអ្នកការពារ ឬមានបំណងចង់ឲ្យគេធ្វើឲ្យតំណាង ដោយទីប្រឹក្សាច្បាប់។ នេះតម្រូវឲ្យមានការស៊ើបអង្កេតហើយរបាយគឺមិនតម្រូវ បើសិនជាអ្នកសុំ ការពារនឹងមកចូលរួមក្នុងសវនាការ ហើយនិងបុគ្គលដែលដាក់ពាក្យតវ៉ាសំរាប់អភិរក្សភាព ឬអ្នកដែលមើលលើអភិរក្សភាពរបស់ខ្លួនឯងនោះ។

ពេលណាបានបង្កើតឡើង - អ្នកការពារទ្រព្យសម្បត្តិសុពលកម្ម មិនត្រូវយកមកពិនិត្យមើលវិញ ក៏ប៉ុន្តែ រហូតដល់មនុស្សនោះស្លាប់ ឬ រហូតដល់តែមានបទបញ្ជាពីតុលាការឲ្យបញ្ឈប់។ សុពលកម្មរបស់អ្នករក្សាមានកេរ្តិ៍ឈប់ការទាក់ទងជាមួយអភិរក្សជនមានកេរ្តិ៍/អភិរក្សជនទទួលមានកេរ្តិ៍។ ដើម្បីរកមនុស្សបំពេញមុខងារនេះ ត្រូវតែដាក់ពាក្យទាមទាររកជំនួសអភិរក្សជនមានកេរ្តិ៍។

ក្នុងកំឡុងពេល 90 ថ្ងៃក្រោយបានដាក់តាំង អ្នកការពារមើលទ្រព្យសម្បត្តិទាំងអស់ត្រូវដាក់ពាក្យមកតុលាការ ហើយអ្នកស៊ើបអង្កេតរបស់តុលាការរៀបគំរោងទូទៅបញ្ជាក់ពីសេចក្តីត្រូវការផ្ទាល់ខ្លួន និងប្រាក់កាសនៃអភិរក្សជនទទួលត្រូវធ្វើបែបណានោះ។ លិខិតបញ្ជាក់ការដាក់ពាក្យរបស់គំរោងត្រូវតែបានឲ្យដល់អ្នកទាំងអស់ណាដែលបានទទួលលិខិតដើមនៃការប្តឹងតវ៉ា។ បើសិនជាតុលាការយល់ថា គំរោងនោះមិនមែនជាការល្អសំរាប់អភិរក្សជនទទួល ឬបើសិនជាតុលាការទទួលការជំទាស់ដល់គំរោងក្នុងរយៈពេល 30 ថ្ងៃ ក្រោយពីបានផ្ញើលិខិតដាក់ពាក្យប្តឹងតវ៉ានោះ។

បើសិនជាអភិរក្សភាពមានទំនាក់ទំនងក្នុងការចាត់ចែងទ្រព្យ, ការដាក់ពាក្យប្តឹងតវ៉ាពីការទទួលខុសត្រូវ ត្រូវតែដាក់ទៅតុលាការនៅចុងឆ្នាំដំបូង ក្រោយពីពេលណាត់ជួប ហើយរាល់ពីរឆ្នាំបន្ទាប់មក។ ទោះបីជាការទទួលខុសត្រូវនោះតម្រូវឲ្យមាន, អ្នកស៊ើបអង្កេតតុលាការត្រូវសម្ភាសន៍អភិរក្សជនទទួលម្តងទៀតនៅលើថ្ងៃ ឬនៅប្រហាក់ប្រហែលថ្ងៃកំណត់ខួបនៃការបង្កើតអភិរក្សភាព ហើយនិងរាល់ពីរឆ្នាំបន្ទាប់មក។ គោលបំណងនៃការសម្ភាសន៍ គឺជាសេចក្តីត្រូវការជាចាំបាច់ ដើម្បីប៉ាន់មើលប្រសិនជាអភិរក្សភាពនោះ មានការចាំបាច់បន្ត ហើយបើសិនជាអភិរក្សជនផ្តល់ធ្វើបានល្អចំពោះអភិរក្សជនទទួលដែរឬទេ។ របាយការណ៍របស់អ្នកស៊ើបអង្កេត គឺបានបញ្ជូនទៅតុលាការដោយមានចម្លងឲ្យ



មុនឆ្នាំ 2000 ការខុសចំបងរវាងកម្មវិធីទាំងពីរមានការទាក់ទងទៅនិងការផ្ទេរទ្រព្យសម្បត្តិ។ ដោយការគោរពទៅនិងភារៈគ្រប់គ្រងដែលបានបង្កើតមុនខែមករា ទី 1 ឆ្នាំ 2000, អ្នកទទួលប្រាក់ SSI (ប៉ុន្តែមិនមែនអ្នកទទួលម៉េឌី-ខាលទេ) អាចបង្កើតភារៈគ្រប់គ្រងទ្រព្យសម្បត្តិរបស់អ្នកទទួលប្រាក់ជំនួយនេះ ហើយនៅទទួលប្រាក់ SSI បាន។ ការប្រព្រឹត្តបែបនេះ គឺមិនអាចធ្វើទៅទៀតបាន ដោយលទ្ធផលនៃការផ្លាស់ប្តូរច្បាប់ SSI ហៅថា Foster Care Independence Act of 1999 (H.R. 3443) ។

បច្ចុប្បន្ននេះ ច្បាប់ ម៉េឌី-ខាល និងប្រាក់ SSI ទាំងពីរសង្កត់ទៅលើការបង្កើតភារៈគ្រប់គ្រងរបស់ អ្នកទទួលផលប្រយោជន៍ (បានហៅថាភារៈគ្រប់គ្រង "រៀបចំ-ខ្លួន" ឬ "ក្រុមទីដំបូង")។ បើសិនជាអ្នកទទួលផលប្រយោជន៍បង្កើតភារៈគ្រប់គ្រងទ្រព្យសម្បត្តិក្នុងភារៈគ្រប់គ្រងគិតថាជាប្រភពប្រើ ប្រាសបានដល់អ្នកទទួលផលប្រយោជន៍។ បើសិនជាចំនួនប្រភពប្រើប្រាសបាននោះលើសពី $2,000 អ្នកទទួលផលប្រយោជន៍មិនអាចទទួលម៉េឌី-ខាលបានឡើយ។ បើសិនជាភារៈគ្រប់គ្រងមិនបានបង្កើតដោយអ្នកទទួលផលប្រយោជន៍ ឬអ្នកណាម្នាក់ជំនួសអ្នកទទួលផលប្រយោជន៍ទេ (ដូចជាភារៈគ្រប់គ្រងដែលបានបង្កើតឲ្យកូនដោយឪពុកម្តាយ) ទោះជាទ្រព្យនោះ អាចប្រើប្រាស់បានដោយអ្នកទទួលផលប្រយោជន៍ គឺយោងទៅលើអ្នកទទួលផលប្រយោជន៍ភារៈគ្រប់គ្រងដកហូតមកវិញ ឬត្រួតពិនិត្យមើលការចែកចាយពីភារៈគ្រប់គ្រងនេះ។ បើដូច្នេះ មែនភារៈគ្រប់គ្រងទ្រព្យនេះ គឺជាប្រភពប្រើប្រាសបាន។

មានប្រភេទនៃការរៀបចំ-ខ្លួនមួយដែលមិនធ្វើឲ្យអ្នកទទួលលែងបានទទួលប្រាក់ SSI ហើយនិង ម៉េឌី-ខាល : តុលាការបញ្ជាឲ្យភារៈគ្រប់គ្រងសំរាប់មនុស្សមានភាពពិការដែលមានអាយុតិចជាង 65 ឆ្នាំ នៅពេលភារៈគ្រប់គ្រងនោះបានបង្កើតឡើង បើសិនជារង្វង់សុខចិត្ត

ក៏ប៉ុន្តែភារៈគ្រប់គ្រងមិនពិតប្រាកដឲ្យបានសម្រេចគោលនៃសិទ្ធទទួលប្រាក់ SSI ការស្នើសុំគឺមិន បង្ខំតាមច្បាប់ឡើយ។ ដូច្នេះដែរ អ្នកថែរក្សាប្រាក់កាសនោះ ត្រូវតែបង់ថ្លៃពន្ធដារដែលបានមកពីទ្រព្យសម្បត្តិ ហើយអ្នកឲ្យប្រាក់ខ្ចីរបស់អ្នកថែរក្សាអាចទាមទាទៅនិងប្រាក់កាសនេះ។ ទីបញ្ចប់ បើសិនជាអ្នកកាន់កាប់ប្រាក់កាសនោះស្លាប់ មុនអ្នកទទួលផលប្រយោជន៍មិនពិតប្រាកដប្រាក់កាស នេះនឹងបញ្ជូនទៅឲ្យអ្នកស្នងទ្រព្យដែលសមស្របទៅនិងមត៌កសាសន៍របស់បុគ្គលនោះ។ ដោយសារបញ្ហាទាំងនេះ ភារៈគ្រប់គ្រងមិនពិតប្រាកដមិនសូវយកប្រើប្រាសទេ។

## តើឲ្យមាតាបិតាការពារចំពោះភាពទំនងមានការផ្លាស់ប្តូរច្បាប់អំពីសិទ្ធទទួលប្រាក់ SSI យ៉ាងណាដែរ ?

ការផ្តល់ឲ្យមានសន្ធះសន្តិសុខជាទូទៅគួរតែបូកបញ្ចូលក្នុងបង្ហាញអ្នកទទួលការរក្សាចំពោះការផ្ទេរភារៈគ្រប់គ្រងទ្រព្យសម្បត្តិទាំងអស់ឲ្យទៅអ្នកទទួលការរក្សាមិនពិតប្រាកដ បើសិនជាការគ្រប់គ្រងដែលមាននោះ ធ្វើឲ្យអ្នកផលប្រយោជន៍លែងមានសិទ្ធទទួលប្រាក់ SSI ឬជំនួយសាធារណៈណាផ្សេងទៀត។

ដូច្នេះដែរ មត៌កសាសន៍អាចបូកបញ្ចូលគ្រប់ពេលវេលាមុនពេលមរណៈភាពរបស់ម្ចាស់បណ្តាំ។ តែបើសិនជាច្បាប់មានការផ្លាស់ប្តូរនៅក្នុងរយៈពេលនេះ ការកែទំរង់ភារៈគ្រប់គ្រងប្រហែលជាត្រូវធ្វើឡើង។

## តើច្បាប់ទម្លាប់លើការសិទ្ធទទួលប្រាក់ SSI ដូចគ្នានិងសិទ្ធ ទទួលម៉េឌី-ខាល ឬ ?

ចាប់ផ្តើមពីខែមករា ទី 1 ឆ្នាំ 2000 ច្បាប់ទម្លាប់លើភារៈគ្រប់គ្រងប្រាក់ SSI គឺស្រដៀងទៅនិង ច្បាប់ទម្លាប់ ម៉េឌី-ខាល ដែរ។



ទៅអភិរក្សជនផ្តល់ ឬទៅមេធាវីរបស់បុគ្គលនោះ។ អ្នកស៊ើបអង្កេតប្រហែលជាអាចទៅជួបជាមួយបុគ្គលដែលមិនមែនជាអភិរក្សជនទទួលដើម្បីប៉ាន់មើល បើសិនជាអភិរក្សជនផ្តល់មើលថែទាំបានល្អចំពោះអភិរក្សជនទទួលដែរឬទេ។ អភិរក្សជនទទួលផាកតម្លៃនេះទៅខានធីពីបទស៊ើបអង្កេតដំបូង ហើយនិងការស៊ើបអង្កេតតាមរយៈពេលបន្ទាប់មកទៀត។ ក៏ប៉ុន្តែ បើសិនជាអភិរក្សជនទទួលពុំមានថវិកាគ្រប់គ្រាន់សំរាប់បង់ថ្លៃនោះទេ ឬបើសិនជាការធ្វើដូច្នេះ នាំឲ្យកាន់តែមានផលវិបាកថែមទៀតនោះ តុលាការនិងលុបចោលថ្លៃផាកនេះចេញ។

## តើអ្នកណាអាចធ្វើជាអ្នកការពារសម្បត្តិ ?

បុគ្គលណាម្នាក់ដែលពេញវ័យអាចធ្វើជាអ្នកការពារ បើសិនជាតុលាការបានចាត់ថា បុគ្គលនោះអាច ការពារនូវផលប្រយោជន៍អ្នកទទួលសេចក្តីការពារបានលប្រសើរនោះ។ បើសិនជាមានការប្រណាំងប្រជែងដណ្តើមយកមុខងារនេះ ហើយអ្នកពាក្យសុំនោះមានសមត្ថភាពស្មើគ្នា ច្បាប់បែកចែកមុនស្ស តាមលំដាប់ដូចមានតកត់ចុះទៅនេះ : បេក្ខជនដែលបានគ្រោងនៃអ្នកទទួលការពារ, ប្តីប្រពន្ធបានគ្រោងនៃអ្នកទទួលការពារ, កូនពេញវ័យនៃអ្នកទទួលការពារ, ឪពុកម្តាយគ្រោងនៃអ្នកទទួលការពារ, បងបនប្រុស ឬបងប្អូនស្រីគ្រោងនៃអ្នកទទួលការពារ។ អភិរក្សជំនាញការឯកជនក៏អាចបំរើក្នុងភារៈកិច្ចនេះបានដែរ អោយតែគេដាក់ពាក្យរាល់ឆ្នាំមើលអំពីមនុស្សដែលផ្តល់កិច្ចបំរើអភិរក្សភាពនោះ។

សមាគមន៍ដែលមិនគិតពីចំណេញអាចធ្វើជាអភិរក្សនៃមនុស្សណាម្នាក់ ឬទ្រព្យដីធ្លី **ឬទាំងពីរ** បើសិនជាច្បាប់របស់សមាគមន៍អនុញ្ញាតឲ្យអង្គការរបស់ខ្លួនទទួលយកការណាត់ឲ្យធ្វើ ហើយសមាគមន៍បានផ្តល់កិច្ចបំរើថែរក្សា, ការណែនាំ ឬជំនួយលុយកាក់ដល់អ្នក

ទទួលការពារគ្រោង ក្រោមការពិនិត្យមើលខុសត្រូវដោយអ្នកកាន់សំណុំរឿងមានឡាយសិុន។

មនុស្សពីរនាក់ ឬច្រើនជាងនេះអាចធ្វើជាអភិរក្សជនទទួលរួមគ្នា។ ពីព្រោះអភិរក្សជនផ្តល់ភាគច្រើនត្រូវតែចូលរួមក្នុងសកម្មភាពណាមួយ។ វាច្រើនមានការទើសទែងដល់អភិរក្សជនផ្តល់ច្រើនជាងពីរនាក់។ ផលប្រយោជន៍ល្អក្នុងការមានអភិរក្សជនផ្តល់ច្រើនជាងមួយ, បើសិនជាអភិរក្សជនផ្តល់ម្នាក់ស្លាប់ រីឯម្នាក់ទៀតអាចបន្តភារៈកិច្ចដោយគ្មានចាំដាក់ពាក្យស្នើសុំមុខងារធ្វើជាអភិរក្សជនផ្តល់ជាថ្មីឡើយ។

## នៅត្រង់ចំណុចណា ដែលគួរឲ្យខ្ញុំគិតពីអភិរក្សភាពនោះ ?

ឪពុកម្តាយប្រហែលជាអាចស៊ើបសុំការណែនាំពីមេធាវីអំពីអភិរក្សភាពលើកាលៈទេសៈពីរ : (1) នៅពេលកូនមានកលចរិត ឬកើតមានភាពពិការ (ឬជិត) ទើបមានអាយុ 18 ឆ្នាំ, ហើយ (2) នៅពេលឪពុកម្តាយសរសេរឲ្យមត៌កសាសន៍របស់ខ្លួន។

គំរោងអភិរក្សភាពដូចជាកូនក្មេងបានឈានទៅដល់អាយុ 18 ឆ្នាំ គឺសំខាន់ណាស់ចំពោះបញ្ហាដែលបានពិភាក្សារួមមកហើយនោះ។ នៅពេលព្រាងមត៌កសាសន៍ បុគ្គលនោះត្រូវគិតមើលអំពីអភិរក្សភាពក្នុងព្រឹត្តិការណ៍មនុស្សដែលមានពិការនោះ នឹងត្រូវឲ្យមានការពិនិត្យមើលខុសត្រូវនៅក្រោយពេលឪពុកម្តាយបានស្លាប់។
បើសិនជាដូច្នេះមែន មត៌កសាសន៍ប្រហែលជាយកមកប្រើដើម្បីធ្វើជាបេក្ខជនអភិរក្សដែលនឹងចាត់តាំងទៅលើការចែកថាននៃឪពុកម្តាយទាំងពីរ។ ទោះជាការរើសធ្វើជា បេក្ខជនមិនស្របតាមច្បាប់តុលាការនឹងធ្វើគ្រប់កិច្ចក្នុងការទទួលស្គាល់ លុះត្រាតែមានការបញ្ចុះ បញ្ចូលថាអភិរក្សភាពនោះមិនចាំបាច់មានទេ ឬក៏ថាបុគ្គលដែលបានបេក្ខជនជាអ្នកការពារនោះ មិនផ្តល់ផលប្រយោជន៍បានលចំពោះអ្នកទទួលសេចក្តីការពារឡើយ។



**3. សំណល់ពីទាន** – ដឹកនាំការជួយសង្គ្រោះបំរើមនុស្សដែលកើតមានភាពពិការទទួលអ្វីដែលនៅ សល់ក្នុងភារៈគ្រប់គ្រងក្រោយពីឪពុកម្តាយស្លាប់ទៅ អ្នកទទួលផលប្រយោជន៍ទំនងមិនប្រឆាំងជំទាស់និងច្បាប់ ដោយសារច្បាប់របស់រដ្ឋាភិបាលក្នុងការជួយសង្គ្រោះ ហើយនិងលើកស្ទួយការធ្វើវិភាគទាននេះទៀតផង។

**4. គ្មានថវិការហួស** – ថវិការជំនួយពិសេសគ្រប់គ្រងដែលមានទ្រព្យសម្បត្តិច្រើន គឺចាំបាច់ជួយ ដល់ផលប្រយោជន៍សាធារណៈដល់អ្នកទទួលផលប្រយោជន៍អស់មួយជីវិត ប្រហែលជាទំនងលើកទឹកចិត្តពីអ្នកឲ្យប្រាក់ខ្ចីឲ្យលួកលន់ក្នុងភារៈគ្រប់គ្រងនោះ។ ចំនួនប្រាក់នេះមិនអាចកត់ចុះលើ កូនសៀវភៅនេះបាន ដោយសាររឿងនេះយោងទៅតាមកាលៈទេសៈនៃករណីរបស់បុគ្គលម្នាក់ៗ។ ពីព្រោះតែការស្មុកស្មាញក្នុងផ្នែកនៃគំរោងរៀបចំទ្រព្យសម្បត្តិ ការស្នើសុំឱវាទពីច្បាប់ពីមេធាវីគឺល្អណាស់។

## តើអ្វីដែលជាភារៈគ្រប់គ្រងមិនពិតប្រាកដហើយនៅពេល ណាគួរប្រើ ?

ភារៈគ្រប់គ្រងមិនពិតប្រាកដ គឺមិនមែនជាភារៈគ្រប់គ្រងពិតប្រាកដនោះឡើយ។ វាជាអំណោយឲ្យទៅ មនុស្សផ្សេងទៀត បូកបញ្ចូលជាមួយខសេចក្តីនៃស្មារតីនូវរបៀបទុកដាក់ទ្រព្យសម្បត្តិនោះ។ ឧទាហរណ៍ បើសិនជាឪពុកម្តាយមានការសោមនស្សអំពីច្បាប់ឲ្យទាក់ទងការមានសិទ្ធទទួលប្រាក់ SSI អាចមានការផ្លាស់ប្តូរ ហើយធ្វើឲ្យថវិកាក្នុងភារៈគ្រប់គ្រងដាក់ៗពីគ្នាអាចរាប់ជាប្រភពបាន គេអាចបន់សល់ប្រាក់ពីកេរ្តិ៍ ពួកគេគួរតែដាក់ប្រាក់កាសនោះទៅក្នុងភារៈគ្រប់គ្រងឲ្យបងបនប្រុសស្រីនៃកូនកើតមានភាពពិការ។ មត៌កសាសន៍មានបញ្ចូលសំណើថាឲ្យមនុស្សថែរក្សាទុក ហើយនិងទុកប្រាក់ទាំងនេះសំរាប់កូនដែលមានភាពពិការនោះ។

បុគ្គលនោះត្រូវតែបង្កើតការមានសិទ្ធសុំ ម៉េឌី-ខាលដោយគ្មានការភ្ជាប់ទៅនិងចំនួនប្រាក់ SSI ប៉ុន្តែដោយសមស្រមតាមច្បាប់របស់ម៉េឌី-ខាល។ ឧទាហរណ៍ ប្រដាប់ប្រដាដែលអាចជួយឲ្យបានសម្រេចក្នុងគោលបំណងនេះមាន :

**1. ខដែលមានចែកដាច់ៗពីគ្នា** – បន្ថែមទៅនិងការព្រៀងត្រឹមត្រូវនៃការបែកចែក វាជាការល្អដែល បានប្រាប់ឲ្យអ្នកទទួលការរក្សាដឹងនូវគោលដៅនៃការគ្រប់គ្រង គឺការជួយជំនួសមួយមិនមែនការដាក់ជំនួស, ជំនួយសាធារណៈរបស់អ្នកទទួលផលប្រយោជន៍។ "សេចក្តីត្រូវការពិសេស" បានចែងក្នុងគ្រោងភារៈគ្រប់គ្រងដូចជនតម្រូវមុនសំរាប់រក្សាសុខភាពអ្នកទទួលផលប្រយោជន៍បានល្អ, សន្តិសុខ ហើយសុខុមាលភាពក្នុងភារៈគ្រប់គ្រងពិសេស គឺមិនផ្តល់ឲ្យដោយភ្នាក់ងារសាធារណៈទេ។ ដោយការមានកំរិតអំណាចអ្នកទទួលគ្រប់គ្រង ដើម្បីធ្វើការចែកចាយសំរាប់ "សេចក្តីត្រូវការពិសេស" នៃអ្នកទទួលផលប្រយោជន៍, ឪពុកម្តាយអាចដឹងច្បាស់លាស់ថា ប្រភពផ្តល់ជំនួយសាធារណៈនិងស្វែងរកពេញលេញមុននិងធ្វើការចែកចាយណាមួយ។ ការផ្តល់និងជួយដល់អ្នកទទួលការរក្សាក្នុងការការពារភារៈគ្រប់គ្រងនៃច្បាប់សាធារណៈ បើសិនជាមានការប្រឆាំងពីសាធារណៈ។

**2. ខដែលមានចែកជារោយៗ** – កំណែប្រែនៃភារៈគ្រប់គ្រងដាច់ៗពីគ្នាមួយទៀត គឺបូកបញ្ចូលអ្នក ទទួលផលប្រយោជន៍ច្រើន ហើយអនុញ្ញាតឲ្យអ្នកទទួល "ការប្រោះ" ក្នុងថវិកានៃភារៈគ្រប់គ្រងក្នុងចំណោមអ្នកទទួលផលប្រយោជន៍ច្រើននាក់។ បើសិនជាអ្នកឲ្យប្រាក់ខ្ចីនៃអ្នកទទួលផលប្រយោជន៍ ដែលកើតមានភាពពិការមានបំណងចង់លោភលន់ដក់ភារៈគ្រប់គ្រង, អ្នកឲ្យប្រាក់ខ្ចីត្រូវតែប្រជែងជាមួយនិងផលប្រយោជន៍នៃអ្នកទទួលផ្សេងៗ ដែលគ្មានជំពាក់ដល់ឥណទាយក។



**តើឲ្យខ្ញុំរកមេធាវីដែលមានជំនាញការក្នុងរឿងរ៉ាវនេះដោយ របៀបណា ?**

ចូរទាក់ទងទៅសមាគមន៍សំរាប់ប្រជាពលរដ្ឋដែលមានកលចរិត (ARC) ។ សមាគមន៍ទាំងនេះភាគច្រើនដឹងអំពីមេធាវីនៅក្នុងតំបន់របស់ខ្លួន ដែលមានការពិសោធន៍ក្នុងការណែនាំឪពុកម្តាយដែលមានកូនមានកលចរិត ឬកើតមានភាពពិការ។ បើសិនជាលោកអ្នកនៅតែមិនបានក្នុងរឿងរ៉ាវនេះទេ តុលាការក្រុង និងសមាគមន៍មេធាវីក្នុងខោនធីមានក្រុមបញ្ជូនមេធាវី។

**ការផ្លាស់ប្តូរចំបង់មួយក្នុងអភិរក្សភាពដែលជាលទ្ធផលចេញពីក្រុមបញ្ញាក់មតិកសាសន៍វិសោធនកម្មនៃឆ្នាំ 1979 និងឆ្នាំ 1980**

**A. អភិរក្សភាពមានកំរិត**

**អំណាចអ្វីដែលមានកំរិត ?**

ដូចអ្នកការពារទូទៅ, អភិរក្សមានកំរិតមានការថែរក្សា, ការចិញ្ចឹមបីបាច់ ហើយនិងត្រួតពិនិត្យមើល អ្នកទទួលការពារ លើកលែង**តែមានការស្នើសុំច្បាស់លាស់ទាមទា** ហើយបានអនុញ្ញាតឲ្យដោយតុលាការ, អភិរក្សជន**មានកំរិតពុំមាន**អំណាច ឬការត្រួតដូចតទៅនេះឡើយ :

1. ដើម្បីពិនិត្យមើលកំរិតអភិរក្សជនទទួលកន្លែងរស់នៅ;
2. មានសិទ្ធិបើមើលបញ្ជីរបស់អភិរក្សជនទទួល;
3. ការពារកំរិតសិទ្ធិអភិរក្សជនទទួលក្នុងការរៀបអាពាហ៍ពិពាហ៍;
4. ត្រួតពិនិត្យមើលកំរិតសិទ្ធិអភិរក្សជនទទួលលើការចុះកុងត្រាអ្វីមួយ;

5. ផ្តល់ការយល់ព្រមដល់ក៏រិតព្យាបាលអភិរក្សជនទទួល;

6. ត្រួតមើឡការប្រស្រ័យទាក់ទង ហើយនិងកាមគុណព្រម ទាំងការមានទំនាក់ទំនងគ្នា;

7. ធ្វើការសម្រេចលើការសោមនស្សអ្វីមួយឲ្យអភិរក្សជនទទួលមានក៏រិតចំពោះការអប់រំ។

ក៏ប៉ុន្តែ អភិរក្សជនផ្តល់មានក៏រិតម្នាក់ៗ តម្រូវឲ្យការពារអភិរក្សជនទទួលមានក៏រិត ដូចជាការរស់នៅ ឬការព្យាបាល, ការហ្វឹកហ្វឺន, ការអប់រំ, កិច្ចបំរើខាងសុខភាព និងខាងខួរក្បាល ហើយនិងសង្គម ព្រមទាំងអាជីវកម្មត្រឹមត្រូវ ហើយនិងជួយដល់អភិរក្សជនទទួលមានក៏រិតក្នុងការ បង្កើតឲ្យមានការពឹងផែកខ្លួនឯងនិងម្ចាស់ការ។

គ្រប់ពេលការតវ៉ាដល់អភិរក្សភាពដែលចោតឡើងថា អភិរក្សជនទទួលខ្វះសមត្ថភាពផ្តល់ឲ្យកិច្ច យល់ព្រមដល់ការព្យាបាលសុខភាព ហើយបានសុំតុលាការចេញអំណាចនេះឲ្យអភិរក្សជនផ្តល់ក្នុងភារៈកិច្ចនោះ, ការទាមទានេះត្រូវតែមានការក្រដាសបញ្ជាក់ពីវេជ្ជបណ្ឌិត ប្រកាសថា អភិរក្សជនទទួល ខ្វះសមត្ថភាពផ្តល់ឲ្យកិច្ចយល់ព្រមដល់ការព្យាបាលសុខភាព។ បន្ថែមទៅទៀត អភិរក្សជនផ្តល់មានក៏រិតនៃទ្រព្យសម្បត្តិអំណាចចាត់ចែងទ្រព្យសម្បត្តិរបស់អភិរក្សជនទទួលដែលបានចែងក្នុងបទបញ្ជា នៅពេលគេដាក់មុខតំណែងអោយតែប៉ុណ្ណោះ។

## តើភារៈកិច្ចអ្វីដែលមណ្ឌលផ្តល់កិច្ចបំរើក្នុងតំបន់មានចំពោះអភិរក្សភាពនោះ ?

នៅក្នុងអភិរក្សភាពដែលទាក់ទងនិងមនុស្សដែលមានកើតភាពពិការ (ត្រូវយល់ព្រមនៃអភិរក្សជនទទួលមានក៏រិត) មណ្ឌលផ្តល់កិច្ចបំរើក្នុងតំបន់ត្រូវធ្វើការសង់ប៉ាន់មើលដែលត្រឹមត្រូវដល់អភិរក្សជន



ជាទូទៅ ឪពុកម្តាយច្រើនមានចំណង់ចិត្តថា អ្វីដែលនៅសល់នៃភារៈគ្រប់គ្រងឲ្យទៅកូនផ្សេងៗទៀត បើសិនជានៅរស់រានមានជីវិតនៅឡើយ ឬក៏ឲ្យចៅៗ។

## ទ្រព្យនៅក្នុងភារៈគ្រប់គ្រងពិសេសតម្រូវឲ្យទាមទារសំរាប់ថ្លៃបង់ថែរក្សាប្រចាំលំនៅដែលឧបត្ថម្ភដោយរដ្ឋ ?

អត់ទេ។ នេះគឺយោបល់របស់អ្នកនិពន្ធថាការព្រាងភារៈគ្រប់គ្រងពិសេសគួរតែទុកថវិកាដោយឡែក ណានៅក្នុងភារៈគ្រប់គ្រងពីការទាមទាទៅរដ្ឋឲ្យសងលុយវិញចំពោះការចំណាយបង់ថ្លៃការថែរក្សានៅទីលំនៅដែលរដ្ឋជួយឧបត្ថម្ភនោះ។

ក្រុមសុពលកម្មរដ្ឋកាលីហ្វ័រនីញ៉ាផ្នែក 15306 ផ្តល់ឲ្យគោលនៃភារៈគ្រប់គ្រងពិសេសគ្មានសមត្ថភាពទាមទាឲ្យគេសងលុយវិញ បើសិនជាភារៈគ្រប់គ្រងនោះបានបង្កើតឡើងសំរាប់ឲ្យមនុស្សដែលមានភាពពិការរួមគ្នាជាមួយភាពពិការហើយនិងថ្លង់នៃសមត្ថភាពផ្តល់ថែរក្សាខ្លួនឯង។

ផ្នែក 15306 បានចែងក្នុងច្បាប់នៅខែមករា ទី 1 ឆ្នាំ 1990 លុបមួយផ្នែកនៃសេចក្តីការពារនេះ។ ការបន្ថែមច្បាប់នេះផ្តល់ឲ្យច្រើនគួរសមនៃផ្នែក 15306 ចំពោះការការពារមិនគួរតម្រូវទៅលើភារៈគ្រប់គ្រងដែលធ្វើអ្នកទទួលផលប្រយោជន៍នោះមិនមានសមត្ថភាពទទួលម៉េឌី-ខាលបាន។

ចំពោះមនុស្សដែលទទួលប្រាក់ SSI ការបន្ថែមច្បាប់មិនជាផលវិបាក ពីព្រោះតែមនុស្សនេះអាចទទួល ម៉េឌី-ខាលបានតែម្តង។ មនុស្សដែលរស់នៅក្នុងដែលគ្មានការជួយឧបត្ថម្ភពីរដ្ឋខាងម៉េឌី-ខេត (Medicaid) ឬ មណ្ឌលដែលធ្វើខុសត្រូវពីខោនធី, មណ្ឌលថែរក្សាព្យាបាល, ឬ មណ្ឌល ព្យាបាលប្រហែលជាមិនអាចទទួលប្រាក់ SSI ឡើយ។ ដើម្បី ការពារគ្រប់គ្រងរបស់គេបាន,

ឧទាហរណ៍ អ្នកគ្រប់គ្រងអាចទិញសំបុត្រយន្តហោះពីភារៈគ្រប់គ្រងឲ្យអ្នកទទួលពីក្រុមហ៊ុនយន្តហោះ ឬភ្នាក់ងារទេសចរណ៍ដោយគ្មានការប៉ះពាល់ដល់ប្រាក់ SSI របស់អ្នកទទួលឡើយ។

ប្រាក់ដែលបានទទួលដោយអ្នកទទួលប្រាក់ SSI ក្នុងមួយខែ គឺរាប់ជាប្រាក់ចំណូលសំរាប់ខែនោះ។ ប្រាក់ដែលនៅសេសសល់នៅដើមខែបនាប់ គឺរាប់ជាប្រភពនៃប្រាក់។ បើសិនជាប្រភពរបស់អ្នកទទួលនៅក្រៅពីភារៈគ្រប់គ្រងហួសពីកំរិតប្រាក់ SSI (បច្ចុប្បន្នចំនួន $2,000 សំរាប់មនុស្សម្នាក់) ប្រាក់ SSI និងបញ្ឈប់មួយរយៈ។ ប្រាក់ SSI និងបញ្ឈប់ដែរ បើសិនជាប្រាក់ចំណូលអពលកម្ម ដែលបានមកក្នុងខែណាក៏ដោយពីអាណត្តិព្យាបាលភាពហើយនិងពីប្រភពផ្សេងៗទៀត (ដូចជាប្រាក់សង្គម ជួយដល់ក្មេងពិការពេញវ័យ - Social Security Adult Disabled Child Benefits) លើសចំនួនប្រាក់ SSI បូកនិង $20 ។

នៅពេលណាបានបញ្ឈប់ប្រាក់ SSI នឹងដាក់បញ្ចូលវិញនៅក្នុងខែដែលប្រាក់ចំណូល ហើយនិងប្រភពផ្សេងៗដែលនៅក្នុងកំរិតរបស់ប្រាក់ SSI. ក៏ប៉ុន្តែ បើសិនជាការបញ្ឈប់បណ្តោះអាសន្នបានឡើង 12 ខែ ឬក៏លើសនេះ ត្រូវដាក់ក្រដាសសុំថ្មី។

ការបញ្ឈប់ ឬការបញ្ឈប់បណ្តោះអាសន្ននៃប្រាក់ SSI អាចប៉ះពាល់ដល់ម៉េឌី-ខាល (Medi-Cal) ហើយកិច្ចបំរើជួយនៅតាមផ្ទះ នឹងត្រូវបញ្ឈប់ដែរ។

### តើអ្វីនឹងកើតចំពោះទ្រព្យនៅក្នុងភារៈគ្រប់គ្រងនោះ នៅពេលក្រោយអ្នកទទួលផលប្រយោជន៍មរណភាពទៅ ?

ភារៈគ្រប់គ្រងសុពលកម្មនឹងត្រួតពិនិត្យមើលការចែកចាយទ្រព្យនៅក្នុងភារៈគ្រប់គ្រងក្រោយពេលស្លាប់របស់អ្នកទទួលផលប្រយោជន៍។



ទទួល ហើយនិងបញ្ជូនរបាយការណ៍ទៅតុលាការ។ របាយការណ៍នេះត្រូវបញ្ជាក់ពីភិនភាគ និង កំរិតភាពពិការរបស់អភិរក្សជនទទួល ហើយនិងទីកន្លែងដែលអភិរក្សជនទទួលនោះត្រូវការជំនួយ។ តម្លៃពិនិត្យប៉ាន់មើលដោយមណ្ឌលផ្តល់កិច្ចបំរើក្នុងតំបន់។ យ៉ាងហោចណាស់បានប្រាំថ្ងៃមុននឹងឡើងសវនាការ, របាយការណ៍ចម្លងរបស់មណ្ឌលផ្តល់កិច្ចបំរើក្នុងតំបន់ត្រូវផ្ញើទៅអភិរក្សជនទទួល ហើយនិងទៅអ្នកទាមទារ ហើយ/ឬទៅឲ្យមេធាវីដែលធ្វើជាតំណាងភាគីនោះ។

### តើអាចឲ្យអភិរក្សជនផ្តល់ទូទៅ ជាជាងអភិរក្សជនផ្តល់ មានកំរិតចាត់តាំងឲ្យសំរាប់មនុស្សដែលកើតមានភាពពិការ បានឬទេ ?

បាន។ តុលាការមានការសម្រេចបង្កើតអភិរក្សភាពទូទៅសំរាប់មនុស្សពេញវ័យដែលមានកើតភាពពិការ ហើយខ្វះសមត្ថភាពបំពេញ "ភារៈកិច្ចផ្គត់ផ្គង់សុខភាពខ្លួន, ម្ហូបអាហារ, ខោអាវ ឬផ្ទះសំបែង ឬគ្រប់គ្រងប្រាក់កាសរបស់ខ្លួនបាន។ បើសិនជាតុលាការរកឃើញថា អភិរក្សជនទទួលដែលបានគ្រោងទុកនេះ ខ្វះសមត្ថភាពផ្គត់ផ្គង់ខ្លួនខ្លះ ប៉ុន្តែមិនទាំងអស់នៃភារៈកិច្ចចាំបាច់ ដើម្បីផ្តល់នូវសេចក្តីត្រូវការបានត្រឹមត្រូវដល់សុខភាព, ម្ហូបអាហារ, ខោអាវ ឬផ្ទះសំបែង ឬទុកដាក់ប្រាក់កាសរបស់ខ្លួនបាន តុលាការពុំមានសម្រេចលើការបង្កើតអភិរក្សភាពទូទៅបានទេ - អភិរក្សភាពមានកំរិតត្រូវតែបានបង្កើតឡើងចំពោះរឿងនេះ។

## តើអភិរក្សភាពដែលមានហើយសំរាប់ការពារថែរក្សាមនុស្សកើតមានភាពពិការក្លាយទៅជាអភិរក្សជនផ្តល់មានកំរិតក្រោយពីខែមករា ទី 1 ឆ្នាំ 1981 ឬ?

**ទេ។** អភិរក្សភាពទូទៅដែលទាក់ទងជាមួយមនុស្សកើតមានភាពពិការមិនក្លាយទៅជាអភិរក្សភាពមាន កំរិតតែម្តងនោះទេ ក្រោយពីខែមករា ទី 1 ឆ្នាំ 1981 ។ ផលប្រយោជន៍ច្រើនសំរាប់ឲ្យអភិរក្សភាពមានកំរិត រួមចូលការប៉ាន់ស្មានមើលសិទ្ធិ ហើយនិងបនកណាដែលបានប៉ះពាល់ពីបទបញ្ជារបស់តុលាការ គឺអាចប្រើប្រាស់បានក្រោមច្បាប់អភិរក្សភាពទូទៅ។

## B. អភិរក្សភាពទូទៅ

## តើច្បាប់ថ្មីបាលផ្លាស់ប្តូរអំណាចនិងអាជ្ញាធរនៃអភិរក្សជនផ្តល់ស្រាប់នោះឬ ?

**1. ការយល់ព្រមទៅនិងការព្យាបាល** – តាំងពីខែមករា ទី 1 ឆ្នាំ 1981, អភិរក្សជនផ្តល់គ្មានអំណាចទៅលើការយល់ព្រមដល់ការព្យាបាលសុខភាពឲ្យអភិរក្សជនទទួល លុះត្រាបានស្នើសុំតុលា ការឲ្យបញ្ចេញអនុញ្ញាតឲ្យការយល់ព្រមជំនួស។ ការលើកលែងតែមួយចំពោះច្បាប់នេះថា ការយល់ព្រមបានបញ្ចេញឲ្យដោយគ្មានបទបញ្ជាពីតុលាការបើសិនអភិរក្សជនទទួល**មិនយល់ទាស់**ដល់គ្រោងព្យាបាលនោះ។

បទបញ្ជាអនុញ្ញាតឲ្យការយល់ព្រមជំនួសប្រហែលជាបទមួយដែលពិនិត្យឃើញថា អភិរក្សជនទទួល គ្មានសមត្ថភាពផ្តល់ឲ្យការយល់ព្រមដល់ការព្យាបាលសុខភាពណាមួយ ហើយបានប្រគល់អំណាចទាំងស្រុងនៃការយល់ព្រមឲ្យទៅអភិរក្សជនផ្តល់។ បទបញ្ជាដូចនេះ



## តើមានមធ្យោបាយណាដែលឪពុកម្តាយអាចទុកឲ្យបានលើសពី $2,000 ដល់កូន ហើយមិនធ្វើ ឲ្យកូននោះគ្មានសិទ្ធទទួលប្រាក់ SSI បានទេ ?

បាន។ នៅក្រោមកម្មវិធីសង្គមកិច្ច (Social Security Program Operations Manual) ថវិកាណាដែលបានទុកសំរាប់គ្រប់គ្រងឲ្យបុគ្គលណាម្នាក់ក្នុងភាពត្រូវការចាំបាច់ (សេចក្តីត្រូវការពិសេស) នោះ គឺមិនបញ្ចូលប្រភពនៃផលប្រយោជន៍ ហើយនិងមិនតែប៉ុណ្ណោះមិនបញ្ចូលប្រាក់ $2,000 ក្នុងកំរិតប្រភពនេះឡើយ។ ដើម្បីឲ្យបានទទួលអ្នកទទួលផលប្រយោជន៍នេះមិនអាចព្យួរទុកភារៈគ្រប់គ្រង ឬក៏ត្រួតពិនិត្យចំនួនប្រាក់ ឬក៏បញ្ជូនប្រាក់កាសនេះញឹកញាប់ពីភារៈគ្រប់គ្រង។ វាជាយោបល់មួយដែរចំពោះអ្នកទទួលភារៈគ្រប់គ្រងចាំបាច់ចំពោះការចែកចាយតម្រង់ទៅលើចំណូលអាណត្តិបាលភាព។ បើសិនជាប្រាកចំណូលទាំងអស់ត្រូវតែងចែកចាយតាមរយៈពេលប្រាក់ SSI ប្រហែលជាបន្ថយឬក៏បញ្ឈប់។

## តើអ្វីនឹងកើតឡើងដល់ប្រាក់ SSI នៅពេលថវិកានៅក្នុងភារៈគ្រប់គ្រងបានចែកចាយទៅដល់អ្នកសុំនោះ ?

ថវិកាដែលចែកចេញពីការគ្រប់គ្រងផ្តល់ដល់អ្នកទទួលគឺមិនរាប់បញ្ចូលជាប្រាក់ចំណូលបានមកពីពលកម្មនោះទេ។ ចំនួនសរុបនៃប្រាក់នេះរៀងរាល់ខែក្នុងចំនួន $20 ជាប្រាក់ចំណូលអពលកម្មផ្ទាច់មុខ នឹងបន្ថយប្រាក់ SSI ក្នុងខែនោះ ពីដុល្លារទៅដុល្លារ។

ការចែកចាយប្រាក់ពីការគ្រប់គ្រងទៅមនុស្សទីបី ជាមិនមែនជាអ្នកទទួលផលប្រយោជន៍នេះ គេមិនគិតថាជាប្រាក់ចំណូលអពលកម្មនោះទេដល់អ្នកទទួល បើសិនជាប្រាក់នោះយកមកបង់សំរាប់អ្វីផ្សេងទៀតក្រៅពីម្ហូបអាហារ, ខោអាវនិងទីជំរកនោះ។ នេះមានន័យថា

## ផ្នែកទី 2

## មត៌កសាសន៍និងភារៈគ្រប់គ្រង

### តើគួរឲ្យឪពុកម្តាយដកកូនចេញ ដោយសារតែកូននោះមានកើតភាពពិការពីចំណែកទ្រព្យសម្បត្តិឬ ?

គោលចម្បងមួយនៃគំរោងបែងចែកទ្រព្យសំរាប់គ្រួសារដែលមានកូន ឬសមាជិកគ្រួសារមានវិកលចរិត ឬមានកើតភាពពិការដើម្បីធ្វើយ៉ាងណា ក្រោយពីមរណភាពនៃឪពុកម្តាយទាំងពីរទៅបុគ្គលដែលមានភាពពិការនឹងបន្តទទួលការឧបត្ថម្ភ ហើយនិងការគ្រប់គ្រងពីប្រភពសាធារណៈ។ ផលប្រយោជន៍នៃសាធារណៈនេះ គឺពិតណាស់ដែលបានកើតឡើងដោយសារឪពុកម្តាយគ្មានសមត្ថភាពបង់ថ្លៃថែរក្សាកូនដែលមានភាពពិការអស់ជីវិតរបស់គេ។

ប្រភពសាធារណៈធំនៃការជួយឧបត្ថម្ភដល់មនុស្សដែលមិនអាចថែរក្សាខ្លួនឯងបានដោយទទួលប្រាក់រដ្ឋ អេះ អេះ អាយ (SSI) ។ ច្បាប់ទម្លាប់ដែលមានមកហើយនោះ បានហាមពីឲ្យអ្នកទទួលប្រាក់ SSI មានប្រភពលើកលែងជំនួយជួយដែលមិនលើសពី $2,000 ។

ដើម្បីសម្រួលសមត្ថភាពទទួលប្រាក់ SSI ឪពុកម្តាយត្រូវតែដកកូន ឬសមាជិកក្នុងគ្រួសារដែលមានកើតភាពពិការចេញពីមត៌កភាព។ ការពឹងផ្អែកទាំងស្រុងទៅលើផលប្រយោជន៍សាធារណៈតម្រូវឲ្យការទុកចិត្តថា ថវិកានឹងបន្តឲ្យមានសំរាប់ជួយមនុស្សនេះអស់មួយជីវិត ហើយនិងបង់ថ្លៃនៃសេចក្តីត្រូវការទូទៅទាំងអស់។

ពីព្រោះតែកម្មវិធីជំនួយសាធារណមានសភាពងាយផ្លាស់ប្តូរតាមសកម្មភាពនយោបាយឆាប់រហ័ស ហើយនាំឲ្យគេមិនអាចបង់ថ្លៃត្រូវការចាំបាច់នេះបាន ការដកចេញទាំងស្រុងនៃកូនដែលពិការចេញពីមត៌កសាសន៍ឪពុកម្តាយជាទូទៅមិនជាការល្អទេ។



ត្រូវតែសុំតែម្តង ដោយសារបទបញ្ជានេះ ប្រើលើគ្រប់ប្រភេទនៃការអនុញ្ញាតឲ្យព្យាបាលសុខភាព។ បើសិនជាអភិរក្សជនទទួលអាចមានសមត្ថភាពផ្តល់ឲ្យការយល់ព្រមខ្លះ ដល់ការព្យាបាលនោះ ប៉ុន្តែមិនអាចដល់ការផ្សេងៗ ដូច្នេះ អភិរក្សជនផ្ត លត្រូវរងចាំរហូតដល់ការព្យាបាលតម្រូវឲ្យមាន ហើយស្នើសុំបទបញ្ជាដែលទាក់ទងទៅនិងទំរង់នៃការព្យាបាលបានគ្រោងពិតប្រាកដណាមួយ។

យោងទៅតាមបទ Due Process Incompetence Determinations Act ដែលបានធ្វើឡើងនៅ ក្នុងឆ្នាំ 1996, បុគ្គលនោះមានសមត្ថភាពដើម្បីផ្តល់នូវសេចក្តីយល់ព្រមដល់ការព្យាបាលសុខភាព បើសិនជាបុគ្គលនោះអាចធ្វើបានទាំងអស់ដូចតទៅនេះ :

(a) ឆ្លើយតបដឹងខុសត្រូវនិងវាងវៃដល់សំណួរអំពីការព្យាបាលសុខភាព។

(b) យល់ដឹងចំពោះគោលនិងភាពធ្ងន់ធ្ងរនៃឈឺចាប់ដែលមនុស្សនោះមាន។

(c) យល់ដឹងចំពោះគោលការព្យាបាលសុខភាពដែលបានប្រាប់ដោយអ្នកផ្តល់កិច្ចព្យាបាលសុខភាព។

(d) យល់ដឹងនូវកំរិតអាចមាននិងរយៈវេលានៃផលប្រយោជន៍ ហើយនិងភាពអន្តរាយនៃការព្យា បាលដែលបានតម្រូវឲ្យហើយនិងផលវិបាកនៃការខ្វះក្នុងការព្យាបាល។

(e) យល់ដឹងនៃគោល, ការអន្តរាយ និងផលប្រយោជន៍ជំនួសណាមួយ។

ពិតណាស់ អភិរក្សជន ផ្តល់ប្រហែលជាអាចផ្តល់នូវការយល់ព្រមសំរាប់ព្យាបាល ដែលអាចមានភាពអន្តរាយដល់អភិរក្សជនទទួល។ ដូច្នេះដែរ ច្បាប់**ហាម**ទាំងអភិរក្សជនផ្តល់និងតុលាការពីការអនុញ្ញាតឲ្យប្រើការព្យាបាលរោគដោយមិនថ្នាំសង្កូវឬវះកាត់, ពិធីមនោវះកាត់ ឬ

អ្នកចាត់ចែងថ្នាំសង្កូវណាមួយ។ ការប្រើថ្នាំធ្វើឲ្យលែងមានកូនប្រហែលជាអាចកើតឡើងក្នុងបរិទបនៃអ្នក ការពារមានក៏រិត ប៉ុន្តែនៅក្រោយកាលៈ ទេសៈស្ដួចស្ដើងណាស់។ កាប្រើថ្នាំធ្វើឲ្យលែងមានកូនមិនអាចកើតឡើងបាននៅទីកន្លែងដែលបាន ពិនិត្យថាបុគ្គល់នោះបានដឹងខ្លួនប្រឆាំងនិងការធ្វើឲ្យលែងមានកូននេះ។ ទោះជាគ្មានការប្រឆាំងនេះក៏ដោយ, សំរាប់ការប្រើថ្នាំធ្វើឲ្យលែងមានកូនកើតមានឡើង, ត្រូវធ្វើតាមពិធីពិសេសដែលមានទាក់ទងការការពារច្រើនយ៉ាងចំពោះអ្នកទទួលការថែរក្សាមានក៏រិតនោះ។ ការការពារទាំងនេះមានរួម : ចាំបាច់ចាត់តាំងឲ្យយោបល់ដល់អ្នកទទួលការរក្សាមានក៏រិត, ការចាត់តាំងនៃ "អ្នកសម្រួល" ដើម្បីជួយដល់អ្នកទទួលការរក្សាមានក៏រិត, អ្នកឯកទេសពិសេសធ្វើការសម្ភាសន៍អ្នកទទួលការក្សាមានក៏រិត ហើយនិងធ្វើសេចក្តីយល់ព្រមទៅតុលាការ ហើយនិងស៊ើបសង្កេតពីមណ្ឌលផ្តល់កិច្ចបំរើក្នុងតំបន់ត្រឹមត្រូវណាមួយ។

**2. សមត្ថភាពដែលជាកិច្ចសន្យា** – តាំងពីខែមករា ទី 1 ឆ្នាំ 1981, អ្នកទទួលការរក្សាមិនអាចចូលសំរេចក្នុងកុងត្រា ឬការដកហូតប្រាក់កាសអ្វីលើសពីចំនួនប្រើប្រាសចំណាយចាំបាច់សំរាប់ម្ហូបអាហារនិងខោអាវឡើយ។ ដើម្បីមើលការផ្លាស់ប្តូរមានសារៈសំខាន់នេះ វាជាការចាំបាច់ណាស់ ត្រូវពិនិត្យមើលត្រួសៗពីគោលនៃអ្នកផ្តល់ការរក្សាមុនខែមករា ទី 1 ឆ្នាំ 1981 ។

ពីមុនៗមក មានអភិរក្សភាពពីប្រភេទ: មួយគឺអ្នកផ្តល់ការរក្សាបានកាត់សេចក្តីថាខ្វះសមត្ថកិច្ច ហើយមួយទៀត គឺបុគ្គល់នោះធម្មតា។ កុងត្រារបស់អ្នកផ្តល់ការរក្សា ដែលគេបានបញ្ជាក់ថា ជាមនុស្សខ្វះសមត្ថកិច្ចបានទុកជា**មោឃៈ** ហើយមិនអាចបង្រឹងទោះជាមានកាលៈទេសៈបិទបាំងការ ដកហូតប្រាក់កាសនេះក៏ដោយ។ ការទាក់ទងនិងការដកហូតប្រាក់កាសរបស់អ្នកទទួលការរក្សាបាន ឃើញថា គ្មានការខ្វះ



សមត្ថកិច្ចបានជំរុញ បើសិនជាទំនាក់ទំនងនេះធ្វើទៅជាផលប្រយោជន៏ល្អសំរាប់ឲ្យអ្នកទទួលការរក្សនោះ។

អភិរក្សាភាពមានក៏រិតមិនមានមុនឆ្នាំ 1981។ អំណាចនៃអ្នកទទួលការរក្សាមានក៏រិតទៅនិងកុងត្រា គឺគ្មានការរាំងរាទេ, លុះត្រាតែឬក៏នបណ្តោយទៅនិងនោះប៉ុណ្ណោះ, តុលាការផ្ទេរអំណាចទៅនិងកុងត្រាឲ្យទៅអ្នកផ្តល់ការរក្សាមានក៏រិតនៅពេលសវនាការនៃប្តឹងទាមទានោះ។

ចំពោះមនុស្សពេញវ័យដែលនៅក្រោមការគ្រប់គ្រងរបស់អាណាព្យាបាលដែលមានមុនខែមករា ទី 1 ឆ្នាំ 1981 ហើយសំរាប់អ្នកទទួលការរក្សាដែលបានឃើញថា មិនខ្វះសមត្ថកិច្ច, ច្បាប់ថ្មីនេះមិនមានការផ្លាស់ប្តូរធំណាមួយចំពោះសមត្ថកិច្ចសន្យាមក, ក្រោមលក្ខន្តិកៈច្បាប់ទាំងពីរមុន និងក្រោយ ឆ្នាំ 1981, ដូចជាការទាក់ទងនិងប្រាក់កាសរបស់អ្នកបុគ្គល់នោះ គ្មានការបង្ខំឲ្យធ្វើ, លើកលែងតែជាការចាំបាច់។ អ្នកទទួលការរក្សាដែលមិនចាត់ថាខ្វះសមត្ថកិច្ចមុនខែមករា ទី 1 ឆ្នាំ 1981, បានដកហូតសិទ្ធិធ្វើអំណោយអូតូម៉ាទិចតែម្តង ឬធ្វើកិច្ចយល់ព្រមណាមួយក្រោយពីថ្ងៃនោះមក។ លទ្ធផលគឺជាពិសេសពិបាកសំរាប់មនុស្សចាស់ដែលមានព្រទ្យសម្បត្តិក្រៃលដែលមានសមត្ថភាពនិងចំណង់ចិត្ត ធ្វើអំណោយនៅពេលនៅរស់ ប៉ុន្តែទ្រព្យរបស់គាត់នៅក្រោមការមើលថែរក្សា។

ផ្លូវតែមួយប៉ុណ្ណោះដែលអ្នកទទួលការរក្សាមានសមត្ថកិច្ចប្រហែលជាអាចទុកសិទ្ធិចុះកុងត្រា គឺត្រូវ ស្នើសុំបទបញ្ជាពីតុលាការជាន់ខ្ពស់។ របៀបស្នើសុំបទបញ្ជាដូចនេះ បានចែងក្នុងលក្ខន្តិកៈច្បាប់ក្នុងឆ្នាំ 1981 ។

បើសិនជាលោកអ្នកមានសំណួរអ្វីអំពីការផ្លាស់ប្តូរនៃការអាចអនុវត្តបានក្នុងច្បាប់អភិរក្សភាពដល់សកម្មភាពចំពោះបុគ្គល់ម្នាក់ៗលោកអ្នកគួរតែស៊ើសុំឱវាទពីមេធាវី។